សំណុំសកម្មភាពអប្បបរមាម៉ូឌុលទី ១០

# សម្ភារៈជំនួយការងារ សំរាប់បុគ្គលិកសុខាភិបាល



- ការជួបពិនិត្យថែទាំ នៅមុនពេលសម្រាល
- ការជួបពិនិត្យថែទាំពេលសម្រាល
- ការជួបពិនិត្យថែទាំក្រោយសម្រាល
- ការជួបពិនិត្យដើម្បីផ្តល់ថ្នាំបង្ការ
- ការជួបពិនិត្យថែទាំកុមាឈឺនិង កុមារសុខភាពល្អ
- ជុំចែកចាយគ្រាប់ថ្នាំជីវជាតិអា

USAID
ជំនួយពីពលរដ្ឋអាមេរិក
AED
Academy for Educational Development
A2Z
Micronutrients Sight Innovation

រៀបចំដោយកម្មវិធីជាតិអាហារូបត្ថម្ភ ដោយមានការគាំទ្រពីគំរោងមីក្រូសារជាតិ A2Z
អង្គការបណ្ឌិតសភាសំរាប់ការអភិវឌ្ឍន៏ការអប់រំ (AED), លោក Jan Berkvens
និងក្រុមការងារអាហារូបត្ថម្ភ ខែ មករា ឆ្នាំ ២០០៩

# ការជួបពិនិត្យថែទាំ
# នៅមុនពេលសម្រាល



រាក់ទាក់

ញញឹម

ស្តាប់

## ០១ ជាដំបូងត្រូវធ្វើការវាយតម្លៃរហ័សដើម្បីរកសញ្ញាដែលត្រូវសង្គ្រោះបន្ទាន់

- ពិនិត្យផ្លូវដង្ហើម និងដង្ហើម
- ស្លេក-ស្បែកត្រជាក់ស្អិត,ជីពចរញាប់ហើយខ្សោយ>១១០ក្នុង១នាទី សំពាធឈាមស៊ីស្តូល < ៩0mmHg
- ធ្លាក់ឈាមតាមទ្វារមាស
- ប្រកាច់ឬបាត់ស្មារតី
- មានការឈឺចាប់នៅក្នុងពោះខ្លាំង
- គ្រុនក្តៅខ្លាំង >៣៨ ដឺក្រេសេ

ផ្តល់ការព្យាបាលសង្គ្រោះបន្ទាន់ឱ្យបានសមស្របទៅតាមពិធីសារថ្នាក់ជាតិ និងបញ្ជូនជាបន្ទាន់ទៅកាន់មន្ទីរពេទ្យបង្អែក។

## ០២ សាកសួររកសៀវភៅសុខភាពមាតា

ពិនិត្យមើលព័ត៌មាននៅលើសៀវភៅសុខភាពមាតា
បើសិនជាគ្មានសៀវភៅសុខភាពមាតាទេ
សូមផ្តល់ជូនគាត់ ១ក្បាល ហើយសរសេរបំពេញសៀវភៅសុខភាពមាតានោះ

## ០៣ នៅពេលពិនិត្យសុខភាពម្តងៗ

- ធ្វើគារវៈកិច្ចចំពោះស្ត្រី និងធ្វើការណែនាំខ្លួនរបស់អ្នក
- សាកសួរស្ត្រីអំពីអារម្មណ៍របស់គាត់ "តើអ្នកមានការបារម្ភណាមួយដែរឬទេ? "
- ពិនិត្យមើលរយៈពេលនៃការមានផ្ទៃពោះ-ស្ទាបស្ទង់
- សួរស្ត្រី - តើអ្នកមានគំរោងផែនការនឹងទៅសម្រាលកូននៅទីណា? ពន្យល់ពីសារៈសំខាន់នៃការសម្រាលកូននៅគ្រឹះស្ថានសុខាភិបាល ដោយឆ្មបដែលមានជំនាញ
- សួរ - តើមានធ្លាក់ឈាមតាមទ្វារមាសដែរឬទេ តាំងពីការពិនិត្យសុខភាពលើកមុនមក?
- សួរ - តើអ្នកមានអារម្មណ៍ថាកូនក្នុងផ្ទៃកំរើកដែរឬទេ?
- ស្តាប់ចង្វាក់បេះដូងរបស់ទារកក្នុងផ្ទៃ (ក្រោយពីផ្ទៃពោះ៦ខែ)

- ពិនិត្យរកមើលបំរុងក្រឡាភ្លើង-វាស់សំពាធឈាមក្នុងស្ថានភាពអង្គុយ។ បើសំពាធឈាមដ្យាស្តូល ៩0 mmhg ឬលើសពីនេះ ត្រូវពិនិត្យសំពាធឈាមម្តងទៀតក្រោយពីសម្រាករយៈពេល ១ម៉ោង។ សួរស្ត្រីថាតើគាត់មានឈឺក្បាលខ្លាំង ព្រិលភ្នែក ឬមានឈឺនៅចុងដង្ហើមដែរឬទេ។ បើសិនជា មួយម៉ោងក្រោយមក សំពាធឈាមនៅតែលើសពី ៩0mmhg-ចូរបញ្ជូនគាត់ទៅកាន់មន្ទីរពេទ្យបង្អែក។
- ពិនិត្យរកមើលភាពស្លេកស្លាំង-មើលភាពស្លេកស្លាំងនៅលើត្របកភ្នែកខាងក្នុង និងនៅបាតដៃ ប្រសិនបើមានភាពស្លេកស្លាំង ចូរព្យាបាលទៅតាមគោលការណ៍ណែនាំថ្នាក់ជាតិដូចខាងក្រោម
- ពិនិត្យរកមើលសញ្ញាកង្វះជីវជាតិអា (សួរអំពីជំងឺខ្វាក់មាន់) ហើយព្យាបាលទៅតាមគោលការណ៍ណែនាំដូចខាងក្រោម

## ០៤ ព្យាបាលភាពស្លេកស្លាំងនិងបញ្ហាកង្វះជីវជាតិអាទៅតាមគោលការណ៍ណែនាំថ្នាក់ជាតិ

| សញ្ញានៃភាពស្លេកស្លាំង  | | | សញ្ញាកង្វះជីវជាតិអា  | |
|---|---|---|---|---|
| ស្លេកស្លាំងខ្លះៗនៅបាតដៃ | ស្លេកស្លាំងធ្ងន់ធ្ងរនៅបាតដៃ ផ្ទៃពោះអាយុក្រោម ៣៦ សប្តាហ៍ | ស្លេកស្លាំងធ្ងន់ធ្ងរនៅបាតដៃ ផ្ទៃពោះអាយុ ៣៦ សប្តាហ៍ និងលើសពីនេះ | សញ្ញាណាមួយនៃជំងឺស្ងួតភ្នែកសកម្ម (ដំបៅកញ្ចក់ភ្នែក) | ខ្វាក់មាន់ ស្នួតភ្នាសស នៃភ្នែក ស្នាមប៊ីតូត |
| ការព្យាបាល | ការព្យាបាល | ការព្យាបាល | ការព្យាបាល | ការព្យាបាល |
| ១គ្រាប់ ថ្នាំជាតិដែក/អាស៊ីដហ្វូលីក x ២ដង ក្នុងមួយថ្ងៃ (ពេលព្រឹក និងពេលល្ងាច) សំរាប់រយៈពេល ១៤ ថ្ងៃ | ១គ្រាប់ ថ្នាំជាតិដែក/អាស៊ីដហ្វូលីក x ២ដង ក្នុងមួយថ្ងៃ (ពេលព្រឹក និងពេលល្ងាច) សំរាប់រយៈពេល ៣ ខែ | មិនត្រូវផ្តល់ថ្នាំជាតិដែកទេ ត្រូវបញ្ជូនទៅមន្ទីរពេទ្យជាបន្ទាន់ | ថ្ងៃទី១: ២00.000 IU ហើយធ្វើការបញ្ជូនទៅកាន់មន្ទីរពេទ្យឯកទេស។ កត់ត្រានៅលើក្រដាសបញ្ជូនពីដូសជីវជាតិអា ដែលបានផ្តល់ឱ្យ | ១ ដូសលេខ ១0.000 IU ក្នុងមួយថ្ងៃ រយៈពេល ៣0ថ្ងៃ។ បើពុំមានលេខនេះទេ ឱ្យមុលទីវីតាមីន ២គ្រាប់ ក្នុងមួយថ្ងៃ រយៈពេល ៣0 ថ្ងៃ |

*១ ដូស ឬ១គ្រាប់នៃថ្នាំជាតិដែក/អាស៊ីដហ្វូលីកមានជាតិដែក៦0មក្រនិងអាស៊ីដហ្វូលីក ៤00មក្រក្រ*

## ០៥ ផ្តល់ប្រឹក្សាអំពីអាហារូបត្ថម្ភ



- បរិភោគអាហារ ១ពេលបន្ថែមទៀតក្នុងមួយថ្ងៃ (គឺ៤ពេលក្នុងមួយថ្ងៃ ក្នុងអំឡុងពេលមានផ្ទៃពោះ)។ ស្ត្រីគួរឡើងទម្ងន់ ៧គក្រ នៅក្នុងអំឡុងពេលនៃការមានផ្ទៃពោះ
- បរិភោគអាហារចំរុះ ដូចជាត្រី ថ្លើម សាច់ សណ្តែក បន្លែ ផ្លែឈើ តៅហ៊ូ និងប្រេង

ចាប់ផ្តើមបំបៅកូនដោយទឹកដោះម្តាយនៅក្នុងម៉ោងដំបូងបន្ទាប់ពីសម្រាល (បំបៅកូនភ្លាមក្រោយសម្រាល) ធ្វើការបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់ សំរាប់រយៈពេល ៦ខែដំបូង។ ចាប់ផ្តើមផ្តល់អាហារបន្ថែមចាប់ពីកុមារអាយុបាន ៦ខែ។

បន្តធ្វើការបំបៅកូនដោយទឹកដោះម្តាយ រហូតទាល់តែកុមារអាយុបានយ៉ាងតិច ២ឆ្នាំ ឬលើសពីនេះ។

## ០៦ ផ្តល់ប្រឹក្សាអំពីការថែទាំខ្លួនឯង ក្នុងអំឡុងពេលមានផ្ទៃពោះ



- ពិនិត្យផ្ទៃពោះមុនពេលសម្រាលយ៉ាងហោចណាស់ឱ្យបាន៤ដងនៅក្នុងអំឡុងពេលមានផ្ទៃពោះ
- ទៅពិនិត្យផ្ទៃពោះអោយបានឆាប់បន្ទាប់ពីបាត់រដូវ
- សម្រាកឱ្យបានញឹកញាប់ និងចៀសវាងការលើករបស់ធ្ងន់ៗ
- សំរាន្តនៅក្នុងមុងជ្រលក់
- ចៀសវាងជក់បារី និងបរិភោគស្រា (គ្រឿងស្រវឹង)
- មិនត្រូវលេបថ្នាំអ្វីទេ លើកលែងតែវេជ្ជបញ្ជាចេញដោយគ្រឹះស្ថានសុខាភិបាល

## ០៧ លើកកំពស់ការស្រាវជ្រាវរកមេរោគអេដស៍ និងកាមរោគ

បើសិនជាស្ត្រីមានផ្ទៃពោះ នៅមិនទាន់បានធ្វើតេស្តរកមេរោគអេដស៍ និងកាមរោគទេ ចូរបញ្ជូនគាត់ទៅកាន់មូលដ្ឋានសុខាភិបាល ឬអង្គការមិនមែនរដ្ឋាភិបាល ដែលផ្តល់ការធ្វើតេស្ត។ ក៏ដូចគ្នានេះដែរ ចូរជំរុញលើកទឹកចិត្តការធ្វើតេស្តរកមេរោគអេដស៍សំរាប់ដៃគូ។

# ០៨ ជួយស្ត្រីក្នុងការរៀបចំផែនការសម្រាលនិង ផែនការសង្គ្រោះបន្ទាន់

**១. ពន្យល់ពីមូលហេតុដែលគេណែនាំឱ្យគាត់ទៅសម្រាលនៅមូលដ្ឋានសុខាភិបាលៈ**

មូលដ្ឋានសុខាភិបាលមានបុគ្គលិកដែលបានទទួលការបណ្តុះបណ្តាល និងសម្ភារៈផ្គត់ផ្គង់ និងមានប្រព័ន្ធបញ្ជូនក្នុងករណីសង្គ្រោះបន្ទាន់

**២. ពិភាក្សា ពីពិធីនៃការធ្វើដំណើរទៅកាន់មូលដ្ឋានសុខាភិបាល និងការចំណាយសំរាប់ការធ្វើដំណើរ**

**៣. ផ្តល់ដំបូន្មានដល់គាត់អំពីសញ្ញាឈឺពោះសម្រាល**

ជានិច្ចកាល សូមទៅកាន់មូលដ្ឋានសុខាភិបាល បើសិនជាមានសញ្ញាណាមួយ ដូចខាងក្រោមនេះៈ

- ធ្លាក់សមានឈាមស្អិតៗ
- ស្បូនកន្ត្រាក់រាល់ ២០នាទីម្តង ហើយឈឺ
- បែកទឹកភ្លោះ



**៤. ណែនាំគាត់អំពីសញ្ញាគ្រោះថ្នាក់-**

**ត្រូវទៅមូលដ្ឋានសុខាភិបាលជាបន្ទាន់ ប្រសិនបើមាន ៖**

- ធ្លាក់ឈាមតាមទ្វារមាស
- ឈឺក្បាលខ្លាំង ដោយមានព្រិលភ្នែក
- ប្រកាច់
- ហើមមុខ និងម្រាមដៃ ម្រាមជើង
- គ្រុនក្តៅខ្លាំង>៣៨ អង្សាសេ
- ឈឺពោះខ្លាំង
- ដកដង្ហើមពិបាក ឬញាប់

## ០៩ បើសិនជាផ្ទៃពោះស្ថិតនៅក្នុងត្រីមាសទី៣ ចូរអ្នកផ្តល់ប្រឹក្សាអំពីពិធីពន្យាកំណើតនៅក្រោយពេលសម្រាល



- ពិធីសាស្ត្ររយៈពេលខ្លី (LAM= ពិធីធ្វើមិនឱ្យមានរដូវតាមរយៈការបំបៅកូនដោយទឹកដោះម្តាយ)
- ពិធីប្រើប្រាស់ថ្នាំស្តង់ដារពន្យារកំណើតលេបប្រចាំថ្ងៃ
- ថ្នាំចាក់
- ស្រោមអនាម័យ
- ពិធីរយៈពេលយូរ (កងដាក់ក្នុងស្បូន កងដាក់ក្នុងដៃ)
- ពិធីអចិន្ត្រៃយ៍ (ការការពារមិនឱ្យមានកូនដោយធ្វើការវះកាត់តាមការស្ម័គ្រចិត្តរបស់បុរស និងស្ត្រី)

## ១០ ពិនិត្យមើលស្ថានភាពទទួលថ្នាំបង្ការជំងឺតេតាណូសរបស់ស្ត្រី

ពិនិត្យមើលថាតើស្ត្រីបានទទួលថ្នាំបង្ការជំងឺតេតាណូសកាលពីលើកមុនហើយ ឬនៅ។ ធ្វើការសំរេចចិត្តថា តើដូសមួយណាដែលគួរផ្តល់ឱ្យ។ ប្រសិនបើ គ្រប់ដូសទាំងអស់ត្រូវបានផ្តល់ឱ្យរួចហើយកាលពីពេលកន្លងមក មិនត្រូវផ្តល់ឱ្យទៀតទេ។

ដូសទី១ : ក្នុងអំឡុងពេលមកជួបពិនិត្យលើកទី១
ដូសទី២ : យ៉ាងហោចណាស់ ១ខែ ក្រោយពីដូសទី១
ដូសទី៣ : យ៉ាងហោចណាស់ ៦ខែ ក្រោយពីដូសទី២
ដូសទី៤ : យ៉ាងហោចណាស់ ១ឆ្នាំ ក្រោយពីដូសទី៣
ដូសទី៥ : យ៉ាងហោចណាស់ ១ឆ្នាំ ក្រោយពីដូសទី៤

| ១ | ២ | ៣ | ៤ | ៥ |
|---|---|---|---|---|
| ការជួបពិនិត្យលើកទី១ | ១ខែក្រោយពីដូសទី១ | ៦ខែក្រោយពីដូសទី២ | ១ឆ្នាំក្រោយពីដូសទី៣ | ១ឆ្នាំក្រោយពីដូសទី៤ |

## ១១ ផ្ដល់គ្រាប់ថ្នាំជាតិដែក/អាស៊ីដហ្វូលីក





| ការជួប | កំរិតដូស | ចំនួនគ្រាប់ថ្នាំ |
|---|---|---|
| ការជួបលើកទី១ | ១គ្រាប់ថ្នាំជាតិដែក/អាស៊ីដហ្វូលីក លេបប្រចាំថ្ងៃ | ៦០ |
| ការជួបលើកទី២ | ១គ្រាប់ថ្នាំជាតិដែក/អាស៊ីដហ្វូលីក លេបប្រចាំថ្ងៃ | ៣០ |

*១ ដូសឬ១គ្រាប់នៃថ្នាំជាតិដែក/អាស៊ីដហ្វូលីក មានជាតិដែក៦០មក្រអាស៊ីដហ្វូលីក៤០០មក្រក្រ*

- **ពន្យល់អំពីផលរំខាននៃថ្នាំ:** លាមកខ្មៅ មានអារម្មណ៍មិនស្រួលខ្លួន ចង្អោរ រាក ឬទល់លាមក
- ពន្យល់ថាផលរំខានទាំងអស់នេះ ពុំបណ្ដាលឱ្យមានគ្រោះថ្នាក់អ្វីទេ ធ្វើការណែនាំឱ្យគាត់លេបថ្នាំនេះនៅពេលបាយ ឬពេលចូលគេង
- ពន្យល់ណែនាំអំពីអាហារសំបូរជាតិដែក
- ពន្យល់អោយបរិភោគអាហារដែលសំបូរទៅដោយវីតាមីន ដូចជា ផ្លែឈើ និងបន្លែ

## ១២ ផ្ដល់ថ្នាំមេបង់ដាសុល



១ ដូសនៃមេបង់ដាសុល (=៥០០មក្រ)។ ផ្ដល់មេបង់ដាសុល បន្ទាប់ពីខែទីបីនៃផ្ទៃពោះ និងប្រសិនបើមិនទាន់បានទទួលនៅចន្លោះ ៦ខែមុន។

## ១៣ បំពេញសៀវភៅសុខភាពមាតា
## បំពេញទៅក្នុងសៀវភៅកត់ត្រារបស់មណ្ឌលសុខភាព

## ១៤ ធ្វើការចរចារអំពីការត្រលប់មកពិនិត្យលើកក្រោយ



- មកមណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែកដើម្បីពិនិត្យតាមដានឱ្យបាន ៤ ដងក្នុងអំឡុងពេលមានផ្ទៃពោះ។
- មកទទួលគ្រាប់ថ្នាំជាតិដែក/អាស៊ីដហ្វូលិកបន្ថែមចំនួន៣០គ្រាប់ទៀត នៅក្នុងអំឡុងពេលជួបលើកទី២។
- បើសិនជាថ្នាំបង្ការជំងឺតេតាណូស នៅមិនទាន់បានចាក់បង្គ្រប់ទេនោះ ចូររំលឹកម្តាយឱ្យវិលត្រលប់មកវិញ តាមថ្ងៃណាត់ជួបឱ្យបានសមស្រប។
- បើសិនជាមានបញ្ហាណាមួយ ត្រលប់មកកាន់មណ្ឌលសុខភាពជាបន្ទាន់។
- ត្រូវមកមណ្ឌលសុខភាពឬមន្ទីរពេទ្យបង្អែកដើម្បីសម្រាលកូននៅទីនោះ។
- ត្រូវមកមណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែកដើម្បីពិនិត្យថែទាំសុខភាពក្រោយពេលសម្រាលឱ្យបានឆាប់តាមលទ្ធភាពដែលគាត់អាចធ្វើទៅបាន។
- រំលឹកប្រាប់ស្ត្រីអោយយកសៀវភៅសុខភាពមាតាមកជាមួយ នៅរាល់ពេលមកទទួលសេវាពិនិត្យថែទាំសុខភាពម្តងៗ។

# ការជួបពិនិត្យថែទាំ ពេលសម្រាល





រាក់ទាក់

ញញឹម

ស្តាប់

## ០១ ជាដំបូង ត្រូវធ្វើការវាយតម្លៃរហ័សដើម្បីរកសញ្ញា ដែលត្រូវសង្គ្រោះបន្ទាន់

- ពិនិត្យផ្លូវដង្ហើម និងដង្ហើម
- ស្លេក-ស្បែកត្រជាក់ស្អិត ជីពចរញាប់ហើយខ្សោយ >១១០ក្នុង១នាទី សំពាធឈាម ស៊ីស្តូល < ៩០ mmHg
- ធ្លាក់ឈាមតាមទ្វារមាស
- ប្រកាច់ ឬបាត់ស្មារតី
- មានការឈឺចាប់នៅក្នុងពោះខ្លាំង
- គ្រុនក្តៅខ្លាំង > ៣៨ អង្សាសេ

ផ្តល់ការព្យាបាលសង្គ្រោះបន្ទាន់ឱ្យបានសមស្របទៅតាមពិធីសារថ្នាក់ជាតិ និងបញ្ជូនជាបន្ទាន់ទៅកាន់មន្ទីរពេទ្យបង្អែក។

## ០២ ធ្វើតាវកិច្ចចំពោះស្ត្រី និងធ្វើការណែនាំខ្លួនអ្នក ពិនិត្យមើលព័ត៌មាននៅលើសៀវភៅសុខភាពមាតាៗ ប្រសិនបើគ្មានសៀវភៅសុខភាពមាតាទេ សូមផ្តល់ជូនគាត់១ក្បាលហើយសរសេរបំពេញសៀវភៅនោះ

## ០៣ ធ្វើការវាយតម្លៃស្ត្រីក្នុងពេលកំពុងឈឺពោះសម្រាល ឬ បែកទឹកភ្លោះ

**ប្រវត្តិនៃការឈឺពោះឆ្លងទន្លេ:**

- តើការកន្ត្រាក់ស្បូនបានចាប់ផ្តើមតាំងពីពេលណាមក?
- តើការកន្ត្រាក់នេះញឹកញាប់ និងខ្លាំងប៉ុណ្ណាដែរ?
- តើទឹកភ្លោះបែកហើយឬនៅ? តើពណ៌អ្វីដែរ-ពណ៌បៃតង ឬថ្លា?
- តើអ្នកមានធ្លាក់ឈាមខ្លះដែរឬទេ?
- តើទារកមានកំរើកដែរឬទេ?
- តើមានបានទទួលថ្នាំណាមួយដែរឬទេ?
- តើអ្នកមានការព្រួយបារម្ភណាមួយដែរឬទេ?

**ការពិនិត្យរាងកាយ:**

- ពិនិត្យរកមើលភាពស្លេកស្លាំង - ស្លេកស្លាំងនៅបាតដៃ
- ពិនិត្យសំពាធឈាម/សីតុណ្ហភាព
- ស្ទាបពោះរកមើលចលនាកន្ត្រាក់ស្បូន/ភាពញឹកញាប់/រយ:ពេល
- ពិនិត្យមើលការបង្ហាញរបស់ទារក-ក្បាល/គូទ/ផ្នែកផ្សេងៗទៀត?
- តើកូនក្នុងផ្ទៃលើសពីមួយឬ?
- ស្តាប់ចង្វាក់បេះដូងរបស់ទារកក្នុងផ្ទៃ
- បើគ្មានធ្លាក់ឈាមទេ ចូរធ្វើការពិនិត្យទ្វារមាសហើយធ្វើការសំរេចចិត្ត ពីដំណាក់កាលនៃការឈឺពោះសម្រាល

## ០៤ បើមានបញ្ហាផ្នែកសម្ភពចូរធ្វើការព្យាបាលសង្គ្រោះបន្ទាន់ឱ្យបានសមស្របទៅតាមពិធីសារថ្នាក់ជាតិ និងត្រូវបញ្ជូនទៅកាន់មន្ទីរពេទ្យបង្អែកជាបន្ទាន់

**បើសិនជាស្ត្រីឈឺពោះសម្រាលធម្មតាដោយពុំមានបញ្ហាអ្វីទេ នោះ គាត់អាចសម្រាលនៅមណ្ឌលសុខភាពបាន**

- ពិនិត្យតាមដានការឈឺពោះសម្រាលដោយប្រើប៉ាតូក្រាហ្វ និងរៀបចំធ្វើការសម្រាលទៅតាមគោលការណ៍ណែនាំថ្នាក់ជាតិ
- ផ្តល់ការថែទាំគាំទ្រនៅក្នុងអំឡុងពេលឈឺពោះសម្រាល
- ប្រើប្រាស់ការគ្រប់គ្រងសកម្ម។ ដំណាក់កាលទី៣នៃការឈឺពោះសម្រាល ដោយចាក់ អុកស៊ីតូស៊ីន
- ពិនិត្យតាមដានល័ក្ខខ័ណ្ឌរបស់ម្តាយនិងទារកនៅក្រោយពេលសម្រាល ទៅតាមគោលការណ៍ណែនាំថ្នាក់ជាតិ

## ០៥

## ផ្ដល់ការថែទាំចំពោះទារកទើបកើត ទៅតាមគោលការណ៍ណែនាំរបស់ថ្នាក់ជាតិ



- សម្ងួតទារកភ្លាមៗ (មិនងូតទឹកឱ្យទេ)
- វាយតម្លៃពណ៌ និងការដកដង្ហើមរបស់ទារក

ប្រសិនបើ ទារកមិនដកដង្ហើមទេ គៀប ហើយកាត់ទងផ្ចិត រួចរុំ ចាប់ផ្ដើមធ្វើឱ្យដឹងខ្លួនតាមគោលការណ៍ណែនាំថ្នាក់ជាតិ

- ប្រសិនបើ ស្ថិតនៅក្នុងស្ថានភាពល្អ ដាក់ទារកនៅលើដើមទ្រូងរបស់ម្ដាយ ដើម្បីឱ្យស្បែកប៉ះស្បែកជាមួយម្ដាយ ហើយដណ្ដប់ទាំងម្ដាយ និងទារកនឹងភួយ។ ឬរុំទារកនៅក្នុងកន្ទបស្អាតមួយ។
- ដាក់ទារកឱ្យបៅដោះភ្លាមបន្ទាប់ពីសម្រាលរួចក្នុងម៉ោងដំបូង ទោះជានៅមុនពេលទម្លាក់សុកក៏ដោយ
- ពន្យល់ម្ដាយពីសារៈប្រយោជន៍នៃទឹកដោះដំបូង (ទឹកដោះព្រៃ)
- គៀបនិងកាត់ទងផ្ចិត រក្សាវាឱ្យនៅស្ងួត និងទុកឱ្យត្រូវខ្យល់ មិនត្រូវរុំវាទេ
- ថ្លឹងទារក
- ប្រសិនបើទារកតូចពេក (ទម្ងន់តិចជាង២.៥គក្រ) ផ្ដល់ដំបូន្មានដល់ម្ដាយអំពីការបំបៅកូនដោយទឹកដោះម្ដាយ ឱ្យបានញឹកញាប់ រាល់២-៣ម៉ោង ហើយបង្រៀនម្ដាយពីពិធីរក្សាទារកឱ្យមានភាពកក់ក្ដៅ ដោយរួមទាំង (ការដាក់ស្បែកប៉ះស្បែក)
- ផ្ដល់ការព្យាបាលបង្ការជំងឺភ្នែក តាមគោលការណ៍ថ្នាក់ជាតិ
- ផ្ដល់ថ្នាំបង្ការ តាមគោលការណ៍ថ្នាក់ជាតិ - ថ្នាំបង្ការជំងឺរបេង ថ្នាំបង្ការជំងឺរលាកថ្លើមប្រភេទបេ
- ធ្វើការកត់ត្រានៅលើប័ណ្ណសុខភាពកុមារ

# ០៦ ផ្តល់ប្រឹក្សាដល់ម្តាយនិងគ្រួសារ អំពីការបំបៅកូនដោយទឹកដោះម្តាយ





ការផ្អឹបមាត់ទៅនឹងដោះបានល្អ

## សញ្ញានៃការរៀបចំស្ថានភាពបីបំបៅ និងការដាក់មាត់ផ្អឹបទៅនឹងដោះបានល្អ

- ម្តាយមានសភាពសម្រាក និងផាសុកភាព
- រាងកាយរបស់ទារកនៅកៀកជាប់នឹងខ្លួនម្តាយដោយបែរទៅរកដោះ
- ក្បាល និងដងខ្លួនរបស់ទារកសណ្តូកត្រង់
- ចង្ការរបស់ទារកប៉ះទៅនឹងដោះ
- គូថរបស់ទារកត្រូវបានទ្រ
- មាត់របស់ទារក បើកធំ
- បបូរមាត់ខាងក្រោមរបស់ទារករលារចេញក្រៅ
- អណ្តាតរបស់ទារកក្តោបជុំវិញដោះ
- ថ្ពាល់របស់ទារកឡើងប៉ោង
- រង្វង់ខ្មៅជុំវិញដោះត្រូវបានបៅដោយមាត់ទារក
- ទារកជញ្ជក់មួយៗ ខ្លាំងៗ និងសម្រាកម្តងៗ
- អាចមើលឃើញ ឬឮសូរសម្លេងលេបទឹកដោះ
- ទារកនឹងលែង ឬខ្ទាក់ដោះចេញដោយឯងៗ
- ទារកមានសភាពសម្រាក និងងងុយគេង

**ចាប់ផ្តើមបំបៅកូនដោយទឹកដោះម្តាយនៅក្នុងម៉ោងដំបូងបន្ទាប់ពីសម្រាល (បំបៅកូនដោយទឹកដោះម្តាយភ្លាមបន្ទាប់ពីសម្រាល)**

**បំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់រយៈពេល ៦ខែដំបូង (ពន្យល់ពីការបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់)**

# ០៧ ផ្តល់ប្រឹក្សាអំពីអាហារូបត្ថម្ភ





- ផ្តល់ដំបូន្មានដល់ម្តាយឱ្យបរិភោគអាហារ ១ពេលបន្ថែមទៀតក្នុងមួយថ្ងៃ-ត្រូវបរិភោគជាសរុបឱ្យបាន៤ពេលក្នុងមួយថ្ងៃនៅក្នុងអំឡុងពេលដែលគាត់ធ្វើការបំបៅកូនដោយទឹកដោះម្តាយ
- ណែនាំម្តាយឱ្យប្រើប្រាស់តែអំបិលអ៊ីយ៉ូដ សំរាប់គ្រួសារទាំងមូល

## ០៨ ពិនិត្យមើលស្ថានភាពទទួលថ្នាំបង្ការជំងឺតេតាណូសរបស់មាតា

ពិនិត្យមើលថាតើស្ត្រីបានទទួលថ្នាំបង្ការជំងឺតេតាណូសកាលពីលើកមុនហើយ ឬនៅ។ ធ្វើការសំរេចចិត្តថា តើដូសមួយណាដែលគួរផ្តល់ឱ្យ។ ប្រសិនបើ គ្រប់ដូសទាំងអស់ត្រូវបានផ្តល់ឱ្យរួចហើយកាលពីពេលកន្លងមក **មិនត្រូវផ្តល់ឱ្យទៀតទេ។**

ដូសទី១ : ក្នុងអំឡុងពេលមកជួបពិនិត្យលើកទី១
ដូសទី២ : យ៉ាងហោចណាស់ ១ខែ ក្រោយពីដូសទី១
ដូសទី៣ : យ៉ាងហោចណាស់ ៦ខែ ក្រោយពីដូសទី២
ដូសទី៤ : យ៉ាងហោចណាស់ ១ឆ្នាំ ក្រោយពីដូសទី៣
ដូសទី៥ : យ៉ាងហោចណាស់ ១ឆ្នាំ ក្រោយពីដូសទី៤

| ១ | ២ | ៣ | ៤ | ៥ |
|---|---|---|---|---|
| ការជួបពិនិត្យលើកទី១ | ១ខែក្រោយពីដូសទី១ | ៦ខែក្រោយពីដូសទី២ | ១ឆ្នាំក្រោយពីដូសទី៣ | ១ឆ្នាំក្រោយពីដូសទី៤ |

## ០៩ ផ្តល់គ្រាប់ថ្នាំជីវជាតិអាដល់ម្តាយ



- គ្រាប់ថ្នាំជីវជាតិអា ១គ្រាប់ លេខ ២០០,០០០ IU នៅក្នុងរយៈពេល ៦សប្តាហ៍ដំបូង បន្ទាប់ពីសម្រាល។
- ពន្យល់ដល់ស្ត្រីថា ជីវជាតិអាមានសារៈសំខាន់ណាស់សំរាប់សុខភាពរបស់ម្តាយ និងទារក។ ទារកនឹងទទួលបានជីវជាតិអាតាមរយៈទឹកដោះម្តាយ។

## ១០ ផ្តល់គ្រាប់ថ្នាំជាតិដែក/អាស៊ីដហ្វូលិកដល់ម្តាយ





- ផ្តល់ថ្នាំចំនួន ៤២គ្រាប់ ទៅឱ្យម្តាយ បន្ទាប់ពីសម្រាលឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន
- ពន្យល់ថា ម្តាយត្រូវលេបថ្នាំ ១ថ្ងៃ ១គ្រាប់ជារៀងរាល់ថ្ងៃ ( ១គ្រាប់ថ្នាំជាតិដែកអាស៊ីដហ្វូលិកមានជាតិដែក ៦០មក្រ និងអាស៊ីដហ្វូលិក ៤០០មក្រក្រ)

- ពន្យល់អំពីផលរំខាននៃថ្នាំ: លាមកខ្មៅ មានអារម្មណ៍មិនស្រួលខ្លួន ចង្អោរ រាក ឬទល់លាមក
- ពន្យល់ថា ផលរំខានទាំងអស់នេះ ពុំបណ្តាលឱ្យមានគ្រោះថ្នាក់អ្វីទេ។ ធ្វើការណែនាំឱ្យគាត់លេបថ្នាំនេះនៅពេលបាយ ឬពេលចូលគេង
- ពន្យល់អំពី សារៈសំខាន់នៃការបរិភោគអាហារសំបូរជាតិដែក
- ណែនាំអោយបរិភោគអាហារសំបូរវីតាមីន ដូចជា ផ្លែឈើ និងបន្លែ

## ១១ ផ្តល់ថ្នាំមេបង់ដាសុលដល់ម្តាយ



ផ្តល់១ដូស(=៥០០មក្រ)បន្ទាប់ពីសម្រាលឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន

## ១២ បំពេញសៀវភៅសុខភាពមាតានិងប័ណ្ណសុខភាពកុមារ បំពេញទៅក្នុងសៀវភៅកត់ត្រារបស់មណ្ឌលសុខភាព

## ១៣ ធ្វើការចរចារអំពីការត្រលប់មកពិនិត្យលើកក្រោយ ក្នុងកំឡុងពេល ៦ សប្តាហ៍

- ពន្យល់ពីកាលវិភាគនៃការចាក់ថ្នាំបង្ការ នៅសប្តាហ៍ទី៦ ទី១០ ទី១៤
- ប្រសិនបើអ្នក ឬកូនរបស់អ្នកឈឺ ត្រូវត្រលប់មកមណ្ឌលសុខភាពភ្លាម
- រំលឹកប្រាប់ម្តាយឱ្យយកប័ណ្ណសុខភាពម្តាយ និងកុមារមកជាមួយនៅរាល់ពេលមកទទួលសេវាពិនិត្យថែទាំសុខភាព
- ពន្យល់អំពីសារៈសំខាន់នៃការទទួលគ្រាប់ថ្នាំជីវជាតិអា ចាប់ផ្តើមនៅពេលកុមារមានអាយុ ៦ខែ។ កុមារមានអាយុ ពី៦ខែ ដល់ ៥៩ខែ ត្រូវទទួលគ្រាប់ថ្នាំជីវជាតិអា រាល់៦ខែម្តង នៅជុំវិញខែ ឧសភា និង ខែ វិច្ឆិកា។

# ការជួបពិនិត្យថែទាំ
# ក្រោយសម្រាល





រាក់ទាក់
ញញឹម
ស្តាប់

## ០១

## ស្វាគមន៍ម្តាយនិងណែនាំខ្លួនអ្នក សាកសួររកសៀវភៅសុខភាពមាតា ពិនិត្យរកមើលព័ត៌មាននៅលើសៀវភៅសុខភាពមាតា (រួមមានព័ត៌មានលំអិតនៃការសម្រាល)

## ០២

## ធ្វើការវាយតម្លៃសុខភាពរបស់ម្តាយដោយធ្វើការសាកសួរគាត់នូវសំណួរដូចតទៅ៖

- តើអ្នកមានអារម្មណ៍ដូចម្តេចដែរ?
- តើអ្នកមានបញ្ហាអ្វីទេ?
- តើអ្នកមានការឈឺចាប់ ឬគ្រុនក្តៅដែរឬទេ?
- តើកូនរបស់អ្នកយ៉ាងម៉េចដែរ?
- តើការបំបៅដោះកូនរបស់អ្នកយ៉ាងម៉េចដែរ?

**ពិនិត្យមើលសុខភាពរបស់ម្តាយ ទៅតាមពិធីសារជាតិ**

- ពិនិត្យមើលសំពាធឈាម
- ពិនិត្យមើលសីតុណ្ហភាព
- ពិនិត្យមើលស្បូន
- ពិនិត្យមើលដោះ
- ពិនិត្យមើលតំបន់ផ្លូវភេទ - មានហើម/ខ្ទុះ
- ពិនិត្យមើលការធ្លាក់ឈាមតាមទ្វារមាស ឬ កករឈ្លោក
- ពិនិត្យមើលទឹកនោម/លាមក
- ពិនិត្យរកមើលភាពស្លេកស្លាំង - ភាពស្លេកស្លាំងនៅត្របកភ្នែកខាងក្នុង ឬបាតដៃ
- ពិនិត្យរកមើលសញ្ញាកង្វះជីវជាតិអា-ខ្វាក់មាន់ បញ្ហាភ្នែក

ធ្វើការព្យាបាល បើសិនជាចាំបាច់ ដោយប្រើពិធីសារជាតិ ដូចខាងក្រោម:

| សញ្ញានៃភាពស្លេកស្លាំង | | សញ្ញាកង្វះជីវជាតិអា | |
|---|---|---|---|
| ស្លេកស្លាំងខ្លះៗ នៅបាតដៃ | ស្លេកស្លាំងធ្ងន់ធ្ងរ នៅបាតដៃ | សញ្ញណាមួយ នៃជំងឺស្ងួតភ្នែក សកម្ម (ដំបៅ កញ្ចក់ភ្នែក) | ខ្វាក់មាន់ ស្នួតភ្នាសស នៃភ្នែក ស្នាមប៊ីតូត |
| **ការព្យាបាល** | **ការព្យាបាល** | **ការព្យាបាល** | **ការព្យាបាល** |
| ១គ្រាប់ ថ្នាំជាតិដែក/ អាស៊ីដហ្វូលីក X ២ដងក្នុងមួយ ថ្ងៃ (ពេលព្រឹក និងពេលល្ងាច) សំរាប់រយ:ពេល ១៤ ថ្ងៃ | ១គ្រាប់ ថ្នាំជាតិដែក/ អាស៊ីដហ្វូលីក X ២ដងក្នុងមួយ ថ្ងៃ (ពេលព្រឹក និងពេលល្ងាច) សំរាប់រយ:ពេល ៣ខែ | វីតាមីនអាលេខ ថ្ងៃទី១: ២០០.០០០ IU ហើយធ្វើការ បញ្ជូន កត់ត្រានៅប័ណ្ណ បញ្ជូនថា បាន អោយវីតាមីនអា លេខ ២០០.០០០ IU | វីតាមីនអា ១ ដូស លេខ ១០.០០០ IU ក្នុងមួយថ្ងៃ រយ:ពេល៣០ថ្ងៃ។ បើពុំមានលេខ នេះទេ ឱ្យ មុលទីវីតាមីន ២គ្រាប់ក្នុងមួយថ្ងៃ រយ:ពេល ៣០ ថ្ងៃ |

**០៣**

**ស្វែររកប័ណ្ណសុខភាពកុមារ ពិនិត្យមើល ព័ត៌មាននៅលើប័ណ្ណសុខភាពកុមារ បើពុំមានប័ណ្ណសុខភាពកុមារទេ ផ្តល់ប័ណ្ណ សុខភាពកុមារមួយច្បាប់រួចបំពេញប័ណ្ណនេះ**



**ធ្វើការវាយតម្លៃអំពីសុខភាពរបស់ទារកទើបកើតទៅតាម គោលការណ៍ណែនាំថ្នាក់ជាតិ**

សាកសួរម្តាយ ពីការបារម្ភអំពីកូនរបស់គាត់

- វាយតម្លៃអំពីស្ថានភាពទូទៅរបស់ទារក
- ពិនិត្យមើលទម្ងន់
- បើសិនជាទារកតូចពេក (ទម្ងន់ក្រោម២.៥ គក្រ-ទម្ងន់មិនគ្រប់) លើកទឹកចិត្តម្តាយឱ្យធ្វើការបំបៅកូនដោយទឹកដោះម្តាយនៅរាល់ ២-៣ ម៉ោងម្តង
- បង្រៀនម្តាយពីរបៀបរក្សាកំដៅទារកឱ្យមានភាពកក់ក្តៅ (ការដាក់ ឱ្យស្បែកប៉ះស្បែក)

## ០៤

## ធ្វើការសង្កេត វាយតម្លៃនិងផ្តល់ប្រឹក្សាអំពីការបំបៅកូនដោយទឹកដោះម្តាយ



បង្ហាញម្តាយពីរបៀបទ្រខ្លួនទារកត្រឹមត្រូវ ពិនិត្យមើលការដាក់ផ្អឹបមាត់កូនទៅនឹងដោះម្តាយបានល្អ និងជួយគាត់បើចាំបាច់



**ការផ្អឹបមាត់ទៅនឹងដោះបានល្អ**

**សញ្ញានៃការរៀបចំស្ថានភាពបីបំបៅ និងការដាក់មាត់ផ្អឹបទៅនឹងដោះបានល្អ (ប្រសិនបើទារកអាយុតិចជាង ៦ខែ)**

- ម្តាយមានសភាពសម្រាក និងផាសុកភាព
- រាងកាយរបស់ទារកនៅកៀកជាប់នឹងខ្លួនម្តាយដោយបែរទៅរកដោះ
- ក្បាល និងដងខ្លួនរបស់ទារកសណ្តូកត្រង់
- ចង្ការរបស់ទារកប៉ះទៅនឹងដោះ
- គូថរបស់ទារកត្រូវបានទ្រ
- មាត់របស់ទារក បើកធំ
- បបូរមាត់ខាងក្រោមរបស់ទារករលារចេញក្រៅ
- អណ្តាតរបស់ទារកក្តោបជុំវិញដោះ
- ថ្ពាល់របស់ទារកឡើងប៉ោង
- រង្វង់ខ្មៅជុំវិញដោះនៅក្នុងមាត់របស់ទារកច្រើន
- ទារកជញ្ជក់មួយៗ ខ្លាំងៗនិងសម្រាកម្តងៗ
- អាចមើលឃើញ ឬឮសូរសម្លេងលេបទឹកដោះ
- ទារកនឹងលែងឬខ្ជាក់ដោះចេញដោយឯងៗ
- ទារកមានសភាពសម្រាក និងងងុយគេង

**សាកសួរ ប្រសិនបើម្តាយមានការលំបាកណាមួយក្នុងការបំបៅកូនដោយទឹកដោះ**

| ការលំបាកដែលម្តាយជួបប្រទះ | សារសំរាប់ផ្តល់ប្រឹក្សា |
|---|---|
| **ទឹកដោះមានមិនគ្រប់គ្រាន់** | បំបៅដោះកូនរាល់ ២-៣ម៉ោងម្តង។ ត្រូវហូបទឹកយ៉ាងហោចណាស់ឱ្យបាន ២ លីត្រ ក្នុងមួយថ្ងៃ។ ត្រូវបរិភោគអាហារបន្ថែមមួយពេលទៀតក្នុង ១ថ្ងៃ និងអាហារក្រៅពេលដែលសំបូរសារជាតិបំប៉នបន្ថែមទៀត ដូចជាផ្លែឈើជាដើម |
| **ឈាសដោះ** | ត្រូវយកក្រណាត់ស្អាតក្តៅឧណ្ហៗដាក់ស្អំពីលើដោះរយៈពេល៥នាទីមុនពេលបំបៅដោះកូនម្តងៗ។ បើទារកមានការពិបាកក្នុងការដាក់មាត់ផ្អឹបទៅនឹងដោះ ច្របាច់ដោះថ្នមៗ ឱ្យទឹកដោះចេញខ្លះ មុនដាក់ឱ្យកូនបៅ។ បំបៅកូនរៀងរាល់ ២-៣ម៉ោងម្តង ច្របាច់ទឹកដោះដែលនៅសល់ចេញក្រោយពេលបំបៅដោះរួចម្តងៗ |

| ការលំបាកដែលម្ដាយជួបប្រទះ | សារសំរាប់ផ្ដល់ប្រឹក្សា |
|---|---|
| ក្បាលដោះមានស្នាមប្រេះ និងមានការឈឺចាប់ | រក្សាដោះឱ្យស្ងួត និងស្អាតជានិច្ចបន្ទាប់ពីបំបៅម្ដងៗ។ ចាប់ផ្ដើមបំបៅកូននៅខាងដែលមិនសូវឈឺមុន។ នៅពេលបញ្ចប់ការបំបៅ ផ្ដាច់មាត់កូនពីដោះដោយថ្នមៗ |
| ក្បាលដោះលិបចូលក្នុង (ដោះខ្វាក់) | យកតួសេរាំងបឺតទាញក្បាលដោះចេញក្រៅមុនពេលបំបៅដោះកូន |

ផ្ដល់ប្រឹក្សា ស្ដីអំពីការបន្តការបំបៅកូនដោយទឹកដោះម្ដាយ

- បំបៅកូនដោយទឹកដោះម្ដាយតែមួយមុខគត់ រយៈពេល៦ខែដំបូង។
- ចាប់ផ្ដើមផ្ដល់អាហារបន្ថែមចាប់ពីកុមារអាយុបាន ៦ខែ។
- បន្តធ្វើការបំបៅកូនដោយទឹកដោះម្ដាយ រហូតទាល់តែកុមារអាយុបានយ៉ាងតិច ២ឆ្នាំ ឬលើសពីនេះ។




ប្រសិនបើម្ដាយសួរសំណួរ យោងទៅទំព័រស្ដីពីការផ្ដល់អាហារបន្ថែមដែលមាននៅក្នុងសម្ភារៈជំនួយការងារនេះ

## ០៥ ពិនិត្យមើលកុមារនិងម្ដាយរកសញ្ញាគ្រោះថ្នាក់ ហើយនិងធ្វើការបញ្ជូនទៅកាន់មូលដ្ឋានសុខាភិបាល ប្រសិនបើមានសញ្ញាគ្រោះថ្នាក់ណាមួយ

សញ្ញាគ្រោះថ្នាក់ចំពោះទារក:

- ពិបាកដកដង្ហើម
- ប្រកាច់
- ក្ដៅខ្លួន
- រាក
- ត្រជាក់
- កូនតូចពេក
- មិនបៅទាល់តែសោះ

សញ្ញាគ្រោះថ្នាក់ចំពោះម្ដាយ:

- ធ្លាក់ឈាមតាមទ្វារមាសធ្ងន់ធ្ងរ
- ប្រកាច់
- ពិបាកដកដង្ហើម ឬដកដង្ហើមញាប់
- ក្ដៅខ្លួន
- មានការឈឺចាប់នៅក្នុងពោះខ្លាំង

ធ្វើការបញ្ជូនទៅកាន់មន្ទីរពេទ្យជាបន្ទាន់

## ០៦ ផ្តល់ដំបូន្មានអំពីការថែទាំខ្លួនឯង និងអនាម័យ

- ផ្តល់ដំបូន្មានដល់ម្តាយឱ្យសម្រាក និងសំរាន្តឱ្យបានគ្រប់គ្រាន់
- អនាម័យត្រូវងូតទឹកជារៀងរាល់ថ្ងៃ ដើម្បីការពារការបង្ករោគ
- លាងសំអាតប្រដាប់ភេទ ក្រោយពីបន្ទោរបង់រួច
- លាងសំអាតដៃមុនពេលលើក/កាន់ទារក

## ០៧ ផ្តល់ប្រឹក្សាអំពីអាហារូបត្ថម្ភ





- ផ្តល់ដំបូន្មានដល់ម្តាយឱ្យបរិភោគអាហារ ១ពេលបន្ថែមទៀតក្នុងមួយថ្ងៃ ប្រសិនបើបំបៅកូនរបស់ខ្លួនដោយទឹកដោះម្តាយ និងបរិភោគទឹកឱ្យបាន ២លីត្រយ៉ាងតិចក្នុង១ថ្ងៃ។ ផ្តល់ដំបូន្មានឱ្យចៀសវាងការតមអាហារតាមបែបជំនឿ

**ណែនាំម្តាយឱ្យប្រើប្រាស់តែអំបិលអ៊ីយ៉ូដ សំរាប់គ្រួសារទាំងមូល**

## ០៨ ពិនិត្យមើលស្ថានភាពទទួលថ្នាំបង្ការជំងឺតេតាណូសរបស់ម្តាយ

ពិនិត្យមើលថាតើស្ត្រីបានទទួលថ្នាំបង្ការជំងឺតេតាណូសកាលពីលើកមុនហើយ ឬនៅ។ ធ្វើការសំរេចចិត្តថា តើដូសមួយណាដែលគួរផ្តល់ឱ្យ។ ប្រសិនបើ គ្រប់ដូសទាំងអស់ត្រូវបានផ្តល់ឱ្យរួចហើយកាលពីពេលកន្លងមកមិនត្រូវផ្តល់ឱ្យទៀតទេ។

ដូសទី១ : ក្នុងអំឡុងពេលមកជួបពិនិត្យលើកទី១
ដូសទី២ : យ៉ាងហោចណាស់ ១ខែ ក្រោយពីដូសទី១
ដូសទី៣ : យ៉ាងហោចណាស់ ៦ខែ ក្រោយពីដូសទី២
ដូសទី៤ : យ៉ាងហោចណាស់ ១ឆ្នាំ ក្រោយពីដូសទី៣
ដូសទី៥ : យ៉ាងហោចណាស់ ១ឆ្នាំ ក្រោយពីដូសទី៤



## ០៩ ពិនិត្យមើលស្ថានភាពទទួលថ្នាំបង្ការរបស់កុមារ

**ផ្តល់ថ្នាំបង្ការដល់កុមារបើសិនជាចាំបាច់ ចូរប្រើតារាងខាងក្រោមនេះ**

| ក្រុមចំណុច | កំរិតដូស | កំណត់សម្គាល់ |
|---|---|---|
| ទារកទើបសម្រាល | **BCG** : តែ១ដូសគត់<br>**HBO** : តែ១ដូសគត់ | **BCG** អាចផ្តល់បានរហូតដល់កុមារអាយុ១ឆ្នាំក្រោយសម្រាល។ មិនត្រូវផ្តល់ ទេ បើមានរោគសញ្ញាអេចអាយវី<br>**HBO**ត្រូវផ្តល់ក្នុងរយៈពេល២៤ម៉ោង ក្រោយសម្រាល ប៉ុន្តែគេអាចផ្តល់បាននៅក្រោម ៧ថ្ងៃ។ |
| កុមារអាយុក្រោយ ៦សប្តាហ៍ដល់១ឆ្នាំ | **OPV, DPT ឬ DPT-HB**<br>ដូសទី១: ៦សប្តាហ៍ក្រោយសម្រាល<br>ដូសទី២: យ៉ាងហោចណាស់ ៤សប្តាហ៍ក្រោយពីដូសទី១<br>ដូសទី៣: យ៉ាងហោចណាស់ ៤សប្តាហ៍ក្រោយពីដូសទី២<br>**ជំងឺកញ្ជ្រិល** តែ១ដូសគត់ យ៉ាងហោចណាស់អាយុ ៩ ខែ បន្ទាប់ពីសម្រាល | មិនត្រូវខកខានកាលបរិច្ឆេទក្នុងការផ្តល់ថ្នាំបង្ការណាមួយឡើយ។ ថ្នាំបង្ការនឹងមិនមានប្រសិទ្ធភាពឡើយប្រសិនបើមានការខកខានណាមួយនោះ។<br>ចំពោះ **DPT-HB** មិនត្រូវផ្តល់ឱ្យឡើយនៅពេលណាកុមារមានជំងឺធ្ងន់ធ្ងរដោយមានកំដៅឡើងខ្ពស់លើសពី ៣៨,៥អង្សារសេ។<br>មិនត្រូវផ្តល់ **DPT/DPT-HB** បើគេដឹងថាកុមារធ្លាប់មានប្រតិកម្មជាមួយនឹងថ្នាំបង្ការទាំងនេះ។<br>ត្រូវកត់ត្រាការផ្តល់ថ្នាំបង្ការនេះនៅក្នុងប័ណ្ណសុខភាពកុមារ និងក្នុងសៀវភៅកត់ត្រារបស់មណ្ឌលសុខភាព។ |

## ១០ ពិនិត្យមើលម្តាយអំពីការទទួលបានគ្រាប់ថ្នាំជីវជាតិអា នៅក្រោយពេលសម្រាល



ប្រសិនបើមិនទាន់បានទទួលទេ ផ្តល់គ្រាប់ថ្នាំជីវជាតិអា ១ គ្រាប់លេខ ២០០,០០០ IU នៅក្នុងចន្លោះពេល ៦សប្តាហ៍ដំបូងក្រោយសម្រាល។

## ១១ ផ្តល់គ្រាប់ថ្នាំជាតិដែក/អាស៊ីដហ្វូលីកដល់ម្តាយ





- ផ្តល់គ្រាប់ថ្នាំចំនួន ៤២គ្រាប់ នៅពេលជួបពិនិត្យថែទាំក្រោយសម្រាល លើកទី១ ប្រសិនបើគាត់មិនទាន់បានទទួលគ្រាប់ថ្នាំចំនួន ៤២គ្រាប់ នៅពេលសម្រាលទេ
- ត្រូវលេបថ្នាំមួយថ្ងៃមួយគ្រាប់ ជារៀងរាល់ថ្ងៃ
- ពន្យល់អំពីផលរំខាននៃថ្នាំៈ លាមកខ្មៅ មានអារម្មណ៍មិនស្រួលខ្លួន ចង្អោរ រាក ឬទល់លាមក
- ពន្យល់ថា ផលរំខាននៃថ្នាំទាំងអស់នេះ ពុំបណ្តាលឱ្យមានគ្រោះថ្នាក់អ្វីទេ ធ្វើការណែនាំឱ្យគាត់លេបថ្នាំនេះនៅពេលបាយ ឬពេលចូលគេង
- ពន្យល់ណែនាំអំពីអាហារសំបូរជាតិដែក
- ណែនាំអោយបរិភោគអាហារសំបូរវីតាមីនដូចជា ផ្លែឈើ និងបន្លែ

**(ថ្នាំជាតិដែក/អាស៊ីដហ្វូលីក ១គ្រាប់ មានជាតិដែក ៦០មក្រ និង អាស៊ីដហ្វូលីក៤០០ មក្រក្រ)**

## ១២ ផ្តល់ថ្នាំមេបង់ដាសុលដល់ម្តាយ



បើសិនជាម្តាយមិនទាន់បានទទួលថ្នាំនៅពេលសម្រាលទេ ផ្តល់ថ្នាំមេបង់ដាសុល ១ ដូស(=៥០០មក្រ) ក្នុងរយៈពេល ៦ សប្តាហ៍ បន្ទាប់ពីសម្រាលកូនរួច

## ១៣ ផ្តល់ប្រឹក្សាស្តីពីការធ្វើតេស្តឈាមរកមេរោគអេដស៍

- ពិនិត្យមើលស្ថានភាពការធ្វើតេស្តឈាមរកមេរោគអេដស៍
- ប្រសិនបើមិនទាន់បានធ្វើតេស្តទេផ្តល់ប្រឹក្សាស្តីពីការធ្វើតេស្តឈាមរកមេរោគអេដស៍
- ជំរុញលើកទឹកចិត្តដៃគូឱ្យធ្វើតេស្ត
- ផ្តល់ព័ត៌មានអំពីសេវាធ្វើតេស្តដែលនៅជិតជាងគេ

## ១៤

## ផ្តល់ប្រឹក្សាអំពីមធ្យោបាយពន្យារកំណើតក្រោយពេលសម្រាល



ពន្យល់ទៅម្តាយថា ប្រសិនបើគាត់រួមភេទ ហើយមិនបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់ទេ គាត់អាចមានផ្ទៃពោះនៅ ៤សប្តាហ៍ក្រោយពីសម្រាល។ ធ្វើការពិភាក្សាជាមួយគាត់ អំពីការពន្យាកំណើត និងផ្តល់ដំបូន្មានពីចន្លោះពីការមានផ្ទៃពោះមួយទៅផ្ទៃពោះមួយ ឱ្យបាន ២-៣ឆ្នាំ។ ផ្តល់ដំបូន្មានដល់ស្ត្រីអំពីពិធីសាស្ត្រ LAM។

ផ្តល់ដំបូន្មានអំពីមធ្យោបាយពន្យាកំណើតផ្សេងទៀត ដោយប្រើប្រាស់តែមួយ ឬប្រើជាមួយពិធី LAM។ ផ្តល់ដំបូន្មានពីទីកន្លែងដែលគាត់អាចទទួលសេវា និងទទួលការផ្តល់ប្រឹក្សា។

- ពិធីសាស្ត្ររយៈពេលខ្លី (LAM= ពិធីធ្វើមិនឱ្យមានរដូវតាមរយៈការបំបៅកូនដោយទឹកដោះម្តាយ) **ម្តាយដែលបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់ នៅក្នុងអំឡុងពេល៦ខែដំបូង ជាទូទៅអាចការពារគាត់ពីការមានផ្ទៃពោះ ដោយសារគាត់ទំនងមិនផលិតអូវុល។**
- ពិធីប្រើប្រាស់ថ្នាំស្តង់ដារពន្យាកំណើតលេបប្រចាំថ្ងៃ
- ថ្នាំចាក់
- ស្រោមអនាម័យ
- ពិធីរយៈពេលយូរ (កងដាក់ក្នុងស្បូន កងដាក់ក្នុងដៃ)
- ពិធីអចិន្ត្រៃយ៍(ការការពារមិនឱ្យមានកូនដោយធ្វើការវះកាត់តាមការស្ម័គ្រចិត្តរបស់បុរស និងស្ត្រី)

## ១៥

## បំពេញសៀវភៅសុខភាពមាតា
## បំពេញប័ណ្ណសុខភាពកុមារ
## បំពេញ/កត់ត្រាទៅក្នុងសៀវភៅកត់ត្រា
## របស់មណ្ឌលសុខភាព

## ១៦ ធ្វើការចរចារអំពីការត្រលប់មក ពិនិត្យលើកក្រោយ





- ស្ត្រីក្រោយសម្រាល គួរទទួលការពិនិត្យថែទាំក្រោយសម្រាល នៅក្នុងចន្លោះពេល២៤ម៉ោង ២-៣ថ្ងៃ និង ៦សប្តាហ៍
- រំលឹកអំពីកាលវិភាគនៃការចាក់ថ្នាំបង្ការ ៦, ១០, ១៤សប្តាហ៍
- ត្រលប់មកមណ្ឌលសុខភាពភ្លាម នៅពេលណាអ្នក ឬកូនរបស់អ្នកមានជំងឺ
- រំលឹកប្រាប់ម្តាយឱ្យយកប័ណ្ណសុខភាពកុមារមកជាមួយ នៅរាល់ពេលយកកូនមកទទួលសេវាពិនិត្យថែទាំសុខភាព

**រំលឹកអំពីសារៈសំខាន់នៃការទទួលគ្រាប់ថ្នាំជីវជាតិអា ២ដងក្នុង១ឆ្នាំ (នៅជុំវិញខែឧសភា និង ខែវិច្ឆិកា) នៅពេលកុមារមានអាយុចាប់ពី៦ខែ ដល់ ៥៩ខែ នៅតាមភូមិ ឬ នៅមណ្ឌលសុខភាព។**

**" ជីវជាតិអា ជួយសង្គ្រោះជីវិតកុមារ "**

# ការជួបពិនិត្យ ដើម្បីផ្តល់ថ្នាំបង្ការ



រាក់ទាក់

ញញឹម

ស្តាប់

ការជួបពិនិត្យ
ដើម្បីផ្តល់ថ្នាំបង្ការ

**០១** 

**សាកសួររកប័ណ្ណសុខភាពកុមារ**
**សាកសួររកសៀវភៅសុខភាពមាតា**
**ពិនិត្យមើលព័ត៌មាននៅលើប័ណ្ណ**

**០២**

**ពិនិត្យមើលស្ថានភាពទទួលថ្នាំបង្ការរបស់កុមារ**

ផ្តល់ថ្នាំបង្ការដល់កុមារបើសិនជាចាំបាច់ ចូរប្រើតារាងខាងក្រោមនេះ

| ក្រុមចំណុច | កំរិតដូស | កំណត់សម្គាល់ |
| --- | --- | --- |
| ទារកទើបកើត | **BCG** : តែ ១ ដូសគត់<br>**HBO** : តែ ១ ដូសគត់ | **BCG** អាចផ្តល់បានរហូតដល់កុមារអាយុ១ឆ្នាំក្រោយសម្រាល។ មិនត្រូវផ្តល់ទេ បើមានរោគសញ្ញាអេចអាយវី<br>**HBO** ត្រូវផ្តល់ក្នុងរយៈពេល២៤ម៉ោងក្រោយសម្រាល ប៉ុន្តែគេអាចផ្តល់បាននៅក្រោម៧ថ្ងៃ។ |
| កុមារអាយុក្រោយ ៦សប្តាហ៍ដល់១ឆ្នាំ | **OPV, DPT** ឬ **DPT-HB**<br>ដូសទី១: ៦សប្តាហ៍ក្រោយសម្រាល<br>ដូសទី២:យ៉ាងហោចណាស់៤សប្តាហ៍ក្រោយពីដូសទី១<br>ដូសទី៣:យ៉ាងហោចណាស់៤សប្តាហ៍ក្រោយពីដូសទី២<br>**ជំងឺកញ្ជ្រិល**<br>តែ១ដូសគត់ យ៉ាងហោចណាស់ អាយុ ៩ខែ បន្ទាប់ពីសម្រាល | មិនត្រូវខកខានកាលបរិចេទក្នុងការផ្តល់ថ្នាំបង្ការណាមួយឡើយ។ថ្នាំបង្ការនឹងមិនមានប្រសិទ្ធភាពឡើយប្រសិនបើមានការខកខានណាមួយនោះ។<br>ចំពោះ **DPT-HB** មិនត្រូវផ្តល់ឱ្យឡើយនៅពេលណាកុមារមានជំងឺធ្ងន់ធ្ងរ ដោយមានកំដៅឡើងខ្ពស់លើសពី៣៨,៥អង្សារសេ។<br>មិនត្រូវផ្តល់ **DPT/DPT-HB** បើដឹងថាកុមារធ្លាប់មានប្រតិកម្មជាមួយនឹងថ្នាំបង្ការទាំងនេះ។<br>ត្រូវកត់ត្រាការផ្តល់ថ្នាំបង្ការនេះទៅក្នុងប័ណ្ណសុខភាពកុមារនិងក្នុងសៀវភៅកត់ត្រារបស់មណ្ឌលសុខភាព។ |

## ០៣ ពិនិត្យមើលស្ថានភាពទទួលថ្នាំបង្ការជំងឺតេតាណូសរបស់ស្ត្រី

ពិនិត្យមើលថាតើស្ត្រីបានទទួលថ្នាំបង្ការជំងឺតេតាណូសកាលពីលើកមុនហើយ ឬនៅ។ ធ្វើការសំរេចចិត្តអំពីដូសដែលគួរផ្តល់ឱ្យ។ ប្រសិនបើគ្រប់ដូសទាំងអស់ត្រូវបានផ្តល់ឱ្យរួចហើយកាលពីពេលកន្លងមក មិនត្រូវផ្តល់ឱ្យទៀតទេ។

ដូសទី១ : ក្នុងអំឡុងពេលមកជួបពិនិត្យលើកទី១
ដូសទី២ : យ៉ាងហោចណាស់ ១ខែ ក្រោយពីដូសទី១
ដូសទី៣ : យ៉ាងហោចណាស់ ៦ខែ ក្រោយពីដូសទី២
ដូសទី៤ : យ៉ាងហោចណាស់ ១ឆ្នាំ ក្រោយពីដូសទី៣
ដូសទី៥ : យ៉ាងហោចណាស់ ១ឆ្នាំ ក្រោយពីដូសទី៤

| ១ | ២ | ៣ | ៤ | ៥ |
|---|---|---|---|---|
| ការជួបពិនិត្យ លើកទី១ | ១ខែក្រោយពី ដូសទី១ | ៦ខែក្រោយពី ដូសទី២ | ១ឆ្នាំក្រោយពី ដូសទី៣ | ១ឆ្នាំក្រោយពី ដូសទី៤ |

## ០៤ វាយតម្លៃសុខភាពកុមារ សាកសួរម្តាយអំពីការព្រួយបារម្ភដែលគាត់មានចំពោះកូនរបស់គាត់

- វាយតម្លៃសុខភាពរបស់កុមារ-បើមានបញ្ហាណាមួយ ត្រូវធ្វើការព្យាបាលដោយយោងទៅតាមពិធីសារសមាហរណកម្មនៃការទទួលបន្ទុក ពិនិត្យ និងព្យាបាលជំងឺកុមារ (IMCI) និងបញ្ជូន បើសិនជាចាំបាច់
- ពិនិត្យមើលអាយុរបស់កុមារដោយគិតជាសប្តាហ៍ពេញ ខែពេញ និងឆ្នាំពេញ
- ពិនិត្យមើលប្រវែង/កំពស់ (ប្រសិនបើមានឧបករណ៍)
- ពិនិត្យមើលទម្ងន់
- បើសិនជាទារកតូចពេក(ទម្ងន់តិចជាង២,៥គក្រ - មានទម្ងន់មិនគ្រប់) លើកទឹកចិត្តម្តាយឱ្យធ្វើការបំបៅកូនដោយទឹកដោះម្តាយនៅរាល់ ២-៣ ម៉ោងម្តង។

**បង្រៀនម្តាយពីរបៀបរក្សាទារកឱ្យមានភាពកក់ក្តៅ (ពិធីស្បែកប៉ះស្បែក)**

- វាយតម្លៃអំពីទម្ងន់ដោយផ្អែកលើប័ណ្ណសុខភាពកុមារ (ប័ណ្ណលឿង)
- ពន្យល់ម្តាយអំពីទម្ងន់របស់កុមារ និងផ្តល់ប្រឹក្សាទៅតាមទម្ងន់របស់កុមារ។ ជាការសំខាន់ បើសិនជាកុមារមានបញ្ហាកង្វះអាហារូបត្ថម្ភធ្ងន់ធ្ងរ (ហើម ស្គមស្គាំង) ត្រូវបញ្ជូនកុមារទៅកាន់មន្ទីរពេទ្យបង្អែកដែលនៅជិតជាងគេបង្អស់ ដើម្បីធ្វើការព្យាបាល។
- ពិនិត្យរកមើលភាពស្លេកស្លាំង - ធ្វើការព្យាបាលទៅតាមគោលការណ៍ណែនាំថ្នាក់ជាតិ (ដូចដែលមានភ្ជាប់ជូននៅទំព័រខាងក្រោយបង្អស់នៃសម្ភារៈជំនួយការងារនេះ)
- ពិនិត្យរកមើលបញ្ហាកង្វះជីវជាតិអា - ត្រូវធ្វើការព្យាបាល ដោយយោងទៅតាមគោលការណ៍ណែនាំថ្នាក់ជាតិ ដូចដែលមានភ្ជាប់ជូននៅទំព័រខាងក្រោយបង្អស់នៃសម្ភារៈជំនួយការងារនេះ)

## ០៥ ធ្វើការវាយតម្លៃសុខភាពមាតា



### សាកសួរស្ត្រីអំពីការបារម្ភរបស់គាត់ណាមួយ

- ទម្ងន់
- ពិនិត្យមើលសំពាធឈាម
- ពិនិត្យរកមើលសញ្ញានៃភាពស្លេកស្លាំងនៅត្របកភ្នែកខាងក្នុង និងបាតដៃ
- ពិនិត្យរកសញ្ញាកង្វះជីវជាតិអា/ខ្វាក់មាន់
- ផ្តល់ដំបូន្មានដល់គាត់អំពីសារៈសំខាន់នៃរបបអាហារដែលសំបូរសារជាតិចិញ្ចឹម (អាហារ៤ពេលក្នុងមួយថ្ងៃ នៅខណៈដែលម្តាយនៅតែធ្វើការបំបៅកូនដោយទឹកដោះម្តាយ)

## ធ្វើការព្យាបាលភាពស្លេកស្លាំង និងកង្វះជីវជាតិអាទៅតាមគោលការណ៍ណែនាំថ្នាក់ជាតិ

| សញ្ញានៃភាពស្លេកស្លាំង | | | សញ្ញាកង្វះជីវជាតិអា | |
|---|---|---|---|---|
| ស្លេកស្លាំងខ្លះៗ នៅបាតដៃ | ស្លេកស្លាំង ធ្ងន់ធ្ងរនៅ បាតដៃ ផ្ទៃពោះអាយុ ក្រោម ៣៦ សប្តាហ៍ | ស្លេកស្លាំង ធ្ងន់ធ្ងរនៅ បាតដៃ ផ្ទៃពោះអាយុ ៣៦ សប្តាហ៍ និងលើសពីនេះ | សញ្ញាណា មួយនៃជំងឺ ស្ងួតភ្នែកសកម្ម (ដំបៅ កញ្ចក់ភ្នែក) | ខ្វាក់មាន់ ស្នួតភ្នាសស នៃភ្នែក ស្នាមប៊ីតូត |
| **ការព្យាបាល** | **ការព្យាបាល** | **ការព្យាបាល** | **ការព្យាបាល** | **ការព្យាបាល** |
| ១គ្រាប់ ថ្នាំជាតិដែក/ អាស៊ីដហ្វូលីក x ២ដង ក្នុងមួយថ្ងៃ (ពេលព្រឹក និងពេល ល្ងាច) សំរាប់ រយៈពេល ១៤ ថ្ងៃ | ១គ្រាប់ ថ្នាំជាតិដែក/ អាស៊ីដហ្វូលីក x ២ដង ក្នុងមួយថ្ងៃ (ពេលព្រឹក និងពេល ល្ងាច) សំរាប់ រយៈពេល ៣ ខែ តាមដាន រៀងរាល់ ២សប្តាហ៍ | មិនត្រូវផ្តល់ ថ្នាំជាតិដែកទេ ត្រូវបញ្ជូន ទៅមន្ទីរពេទ្យ ជាបន្ទាន់ | ថ្ងៃទី១: វីតាមីនអា ២០០.០០០ IU ហើយបញ្ជូន ទៅកាន់ មន្ទីរពេទ្យ ឯកទេស។ កត់ត្រានៅលើ ក្រដាស បញ្ជូនពីដូស ជីវជាតិអា ដែលបាន ផ្តល់ឱ្យ | វីតាមីនអា ១ ដូស ១០.០០០ IU ក្នុងមួយថ្ងៃ រយៈពេល ៣០ថ្ងៃ។ បើពុំមានលេខ នេះទេ ឱ្យគ្រាប់ថ្នាំ មុលទីវីតាមីន ២គ្រាប់ក្នុង មួយថ្ងៃ រយៈពេល ៣០ថ្ងៃ |

*១ដូស ឬ ១គ្រាប់នៃថ្នាំជាតិដែក/អាស៊ីដហ្វូលីកមានជាតិដែក ៦០មក្រ និងអាស៊ីដហ្វូលីក ៤០០មក្រក្រ*

# ០៦

# ធ្វើការវាយតម្លៃនិងផ្តល់ប្រឹក្សា អំពីការបំបៅកូនដោយទឹកដោះម្តាយ



## សញ្ញានៃការរៀបចំស្ថានភាពបីបំបៅ និងការដាក់មាត់ផ្ទឹបទៅនឹងដោះបានល្អ (ប្រសិនបើទារក អាយុតិចជាង៦ខែ)



**ការផ្ទឹបមាត់ទៅនឹងដោះបានល្អ**

- ម្តាយមានសភាពសម្រាក និងផាសុកភាព
- រាងកាយរបស់ទារកនៅកៀកជាប់នឹងខ្លួនម្តាយដោយបែរទៅរកដោះ
- ក្បាល និងដងខ្លួនរបស់ទារកសណ្តូកត្រង់
- ចង្ការរបស់ទារកប៉ះទៅនឹងដោះ
- គូថរបស់ទារកត្រូវបានទ្រ
- មាត់របស់ទារក បើកធំ
- បបូរមាត់ខាងក្រោមរបស់ទារករលារចេញក្រៅ
- អណ្តាតរបស់ទារកក្តោបជុំវិញដោះ
- ថ្ពាល់របស់ទារកឡើងប៉ោង
- រង្វង់ខ្មៅដោះនៅក្នុងមាត់របស់ទារកច្រើន
- ទារកជញ្ជក់មួយៗ ខ្លាំងៗនិងសម្រាកម្តងៗ
- អាចមើលឃើញ ឬឮសូរសម្លេងលេបទឹកដោះ
- ទារកលែងឬខ្ទាក់ដោះចេញដោយឯងៗ
- ទារកមានសភាពសម្រាក និងងងុយគេង

## សាកសួរ ថាតើម្តាយមានការលំបាកណាមួយក្នុងការបំបៅកូនដោយទឹកដោះម្តាយដែរឬទេ ហើយធ្វើការផ្តល់ប្រឹក្សាដូចខាងក្រោម

| ការលំបាកដែលម្តាយជួបប្រទះ | សារសំរាប់ផ្តល់ប្រឹក្សា |
|---|---|
| **ទឹកដោះមានមិនគ្រប់គ្រាន់** | បំបៅដោះកូនរាល់ ២-៣ម៉ោងម្តង។ ត្រូវហូបទឹកយ៉ាងហោចណាស់ឱ្យបាន ២ លីត្រ ក្នុងមួយថ្ងៃ។ ត្រូវបរិភោគអាហារបន្ថែមមួយពេលទៀតក្នុង ១ថ្ងៃ និងអាហារក្រៅពេលដែលសំបូរសារជាតិបំប៉នបន្ថែមទៀត ដូចជាផ្លែឈើជាដើម |
| **លាសដោះ** | ត្រូវយកក្រណាត់ស្អាតក្តៅឧណ្ហៗដាក់ស្អំពីលើដោះរយៈពេល៥នាទីនៅមុនពេលបំបៅដោះកូនម្តងៗ។ បើទារកមានការពិបាកក្នុងការដាក់មាត់ផ្ទឹបទៅនឹងដោះ ច្របាច់ដោះថ្នមៗឱ្យទឹកដោះចេញខ្លះ មុនដាក់ឱ្យកូនបៅ។ បំបៅកូនរៀងរាល់ ២-៣ម៉ោងម្តង ច្របាច់ទឹកដោះដែលនៅសល់ចេញនៅក្រោយពេលបំបៅដោះរួចម្តងៗ។ |

| ការលំបាកដែលម្ដាយជួបប្រទះ | សារសំរាប់ផ្ដល់ប្រឹក្សា |
|---|---|
| ក្បាលដោះមានស្នាមប្រេះ និងមានការឈឺចាប់ | រក្សាដោះឱ្យស្ងួត និងស្អាតជានិច្ចបន្ទាបពីបំបៅម្ដងៗ។ ចាប់ផ្ដើមបំបៅកូននៅខាងដែលមិនសូវឈឺមុន។ នៅពេលបញ្ចប់នៃការបំបៅផ្ដាច់មាត់កូនពីដោះដោយថ្នមៗ |
| ក្បាលដោះលឹបចូលក្នុង (ដោះខ្វាក់) | យកត្បូសេរាំងបឺតទាញក្បាលដោះចេញក្រៅមុនពេលបំបៅដោះកូន |

**ផ្ដល់ប្រឹក្សា អំពីការបន្តការបំបៅកូនដោយទឹកដោះម្ដាយ**

- បំបៅកូនដោយទឹកដោះម្ដាយតែមួយមុខគត់ រយៈពេល៦ខែដំបូង។
- ចាប់ផ្ដើមផ្ដល់អាហារបន្ថែមចាប់ពីកុមារអាយុបាន ៦ខែ។
- បន្តធ្វើការបំបៅកូនដោយទឹកដោះម្ដាយ រហូតទាល់តែកុមារអាយុបាន យ៉ាងតិច ២ឆ្នាំ ឬលើសពីនេះ។




**សូមមើលទំព័រស្ដីពីការផ្ដល់អាហារបន្ថែម ដែលមាននៅក្នុងសម្ភារៈជំនួយការងារនេះ**

## ០៧ ពិនិត្យមើលម្ដាយអំពីការទទួលបានគ្រាប់ថ្នាំជីវជាតិអា នៅពេលសម្រាលឬនៅ ពេលជួបពិនិត្យថែទាំក្រោយសម្រាល



ប្រសិនបើមិនទាន់បានទទួលទេ ផ្ដល់គ្រាប់ថ្នាំជីវជាតិអា ១គ្រាប់ លេខ ២០០,០០០ IU (នៅក្នុងចន្លោះពេល៦សប្ដាហ៍ដំបូងក្រោយសម្រាលតែប៉ុណ្ណោះ)

## ០៨ ពិនិត្យមើលម្ដាយអំពីការទទួលបានគ្រាប់ថ្នាំជាតិដែក/អាស៊ីដហ្វូលីកនៅពេលសម្រាលឬនៅពេលជួបពិនិត្យថែទាំក្រោយសម្រាល





- ប្រសិនបើមិនទាន់បានទទួលទេ ផ្ដល់ថ្នាំចំនួន ៤២គ្រាប់ឱ្យម្ដាយត្រូវលេបថ្នាំមួយថ្ងៃមួយគ្រាប់ជារៀងរាល់ថ្ងៃ (ថ្នាំជាតិដែក/អាស៊ីដហ្វូលីក ១គ្រាប់មានជាតិដែក ៦០មក្រ និងអាស៊ីដហ្វូលីក៤០០មក្រក្រ)



- ពន្យល់អំពីផលរំខាននៃថ្នាំ: លាមកខ្មៅ មានអារម្មណ៍មិនស្រួលខ្លួន ចង្អោរ រាក ឬទល់លាមក
- ពន្យល់ថា ផលរំខាននៃថ្នាំទាំងអស់នេះ ពុំបណ្តាលឱ្យមានគ្រោះថ្នាក់អ្វីទេ ណែនាំឱ្យគាត់លេបថ្នាំនេះនៅពេលបាយ ឬពេលចូលគេង
- ពន្យល់ណែនាំអំពីអាហារសំបូរជាតិដែក
- ណែនាំអោយបរិភោគអាហារសំបូរជាតិវីតាមីន ដូចជា ផ្លែឈើ និងបន្លែ

## ០៩ ពិនិត្យមើលម្តាយអំពីការទទួលបានថ្នាំមេបង់ដាសុល នៅពេលសម្រាលនិងនៅក្រោយពេលសម្រាល



- បើមិនទាន់បានទទួលថ្នាំទេ ផ្តល់ឱ្យម្តាយ ១ ដូស (=៥០០មក្រ)

## ១០ បំពេញប័ណ្ណសុខភាពកុមារ
## បំពេញសៀវភៅសុខភាពមាតា
## បំពេញបញ្ជីកត់ត្រារបស់មណ្ឌលសុខភាព

## ១១ ធ្វើការចរចារអំពីការត្រលប់មក ពិនិត្យលើកក្រោយ





- ត្រលប់មកមណ្ឌលសុខភាពភ្លាម នៅពេលណាអ្នក ឬកូនរបស់អ្នកមានជំងឺ
- រំលឹកប្រាប់ម្តាយឱ្យយកប័ណ្ណសុខភាពកុមារមកជាមួយ នៅរាល់ពេលមកទទួលសេវាពិនិត្យថែទាំសុខភាព

**រំលឹកអំពីសារៈសំខាន់នៃការទទួលគ្រាប់ថ្នាំជីវជាតិអា ២ដង ក្នុង១ឆ្នាំ (នៅជុំវិញខែឧសភា និង ខែវិច្ឆិកា) នៅពេលកុមារមានអាយុចាប់ពី៦ខែ ដល់ ៥៩ខែ**

**" ជីវជាតិអា ជួយសង្គ្រោះជីវិតកុមារ "**

**មន្ទីរពេទ្យ ដែលផ្តល់ការព្យាបាលជំងឺភ្នែកដោយបញ្ហាកង្វះជីវជាតិអាធ្ងន់ធ្ងរ**

| ខេត្ត | ឈ្មោះមន្ទីរពេទ្យ |
|---|---|
| ភ្នំពេញ | មន្ទីរពេទ្យអង្គឌួង (ផ្លូវ ១១០ ភ្នំពេញ) |
| កណ្តាល | មន្ទីរពេទ្យជ័យជំនះ (ស្រុកតាខ្មៅ) |
| សៀមរាប | មន្ទីរពេទ្យកុមារអង្គរ |
| តាកែវ | មន្ទីរពេទ្យខេត្ត |


ចូរផ្តល់អាហារបន្ថែមទៅលើទឹកដោះម្តាយអោយបានទៀងទាត់ តាមអាយុរបស់កុមារ
៦ ខែ
៧-៨ ខែ
៩-១១ ខែ
១២ ខែឡើង
USAID

# ការជួបពិនិត្យ ថែទាំកុមារឈឺនិង កុមារសុខភាពល្អ



រាក់ទាក់
ញញឹម
ស្តាប់

០១ **សាកសួររកប័ណ្ណសុខភាពកុមារ ពិនិត្យមើលព័ត៌មាននៅលើប័ណ្ណសុខភាពកុមារ**

០២ **សាកសួរម្ដាយអំពីការព្រួយបារម្ភដែលគាត់មានចំពោះកូនរបស់គាត់**

- វាយតម្លៃសុខភាពរបស់កុមារ-បើមានបញ្ហាណាមួយ ត្រូវធ្វើការព្យាបាល ដោយយោងទៅតាមពិធីសារសមាហរណកម្មនៃការទទួលបន្ទុកពិនិត្យ និងព្យាបាលជំងឺកុមារ (IMCI) និងត្រូវបញ្ជូនបើសិនជាចាំបាច់
- ពិនិត្យមើលអាយុរបស់កុមារដោយគិតជាសប្ដាហ៍ពេញ ខែពេញ និងឆ្នាំពេញ
- ពិនិត្យមើល ប្រវែង/កំពស់ (ប្រសិនបើមានឧបករណ៍)
- ពិនិត្យមើលទម្ងន់
- បើសិនជាទារកតូចពេក (ទម្ងន់ទាបជាង ២,៥គក្រ - មានទម្ងន់មិនគ្រប់) ជំរុញលើកទឹកចិត្តម្ដាយឱ្យធ្វើការបំបៅកូនដោយទឹកដោះម្ដាយនៅរាល់២-៣ ម៉ោងម្ដង។ បង្រៀនម្ដាយពីរបៀបរក្សាទារកឱ្យមានភាពកក់ក្ដៅ (ពិធីស្បែកប៉ះស្បែក)
- វាយតម្លៃអំពីទម្ងន់ដោយផ្អែកលើប័ណ្ណសុខភាពកុមារ(ប័ណ្ណលឿង)
- ពន្យល់ម្ដាយអំពីទម្ងន់របស់កុមារ និងផ្ដល់ប្រឹក្សា។ ការសំខាន់ បើសិនជាកុមារមានបញ្ហាកង្វះអាហារូបត្ថម្ភធ្ងន់ធ្ងរ (ហើមស្គមស្គាំង) ត្រូវបញ្ជូនកុមារទៅកាន់មន្ទីរពេទ្យបង្អែកដែលនៅជិតជាងគេបង្អស់ ដើម្បីធ្វើការព្យាបាល។

០៣ **ពិនិត្យរកមើលសញ្ញាកង្វះមីក្រូសារជាតិ**

- ពិនិត្យរកមើលភាពស្លេកស្លាំង (ស្លេកស្លាំងនៅបាតដៃ) ហើយបើសិនមានភាពស្លេកស្លាំង ត្រូវធ្វើការព្យាបាល ដោយយោងទៅតាមគោលការណ៍ណែនាំនៃសមាហរណកម្មនៃការទទួលបន្ទុកពិនិត្យនិងព្យាបាលជំងឺកុមារ (មើលគោលការណ៍ណែនាំនៅទំព័រក្រោយ)
- ពិនិត្យរកមើលបញ្ហាកង្វះជីវជាតិអា ហើយត្រូវធ្វើការព្យាបាល បើសិនជាចាំបាច់។

**ត្រូវធ្វើការព្យាបាល ដោយយោងទៅតាមគោលការណ៍ណែនាំថ្នាក់ជាតិស្ដីពីជីវជាតិអា។ ត្រូវបញ្ជូនកុមារ បើសិនជាចាំបាច់។**

## តារាងព្យាបាលភាពស្លេកស្លាំង និងជីវជាតិអា សំរាប់កុមារ

| រោគសញ្ញាជំងឺ | ក្រុមអាយុ | កំរិតដូស |
|---|---|---|
| រាកជាប់បន្ត/ កង្វះអាហារ រូបត្ថម្ភធ្ងន់ធ្ងរ | ០-៥ ខែ | ជីវជាតិអា ៥០,០០០ IU (១ ដូស) |
| | ៦-១១ ខែ | ជីវជាតិអា ១០០,០០០ IU (១ ដូស) |
| | ១-១២ ឆ្នាំ | ជីវជាតិអា ២០០,០០០ IU (១ ដូស) |
| កង្វះជីវជាតិអា សញ្ញា ៖<br>• ខ្វាក់មាន់<br>• ជំងឺស្ងួតភ្នែក<br>• ស្នាមប៊ីតុត | ០-៥ ខែ | ជីវជាតិអាថ្ងៃទី១ ១ដូស៥០,០០០ IU<br>ជីវជាតិអាថ្ងៃទី២ ១ដូស៥០,០០០ IU<br>ជីវជាតិអាថ្ងៃទី១៤ ១ដូស៥០,០០០ IU |
| | ៦-១១ ខែ | ជីវជាតិអាថ្ងៃទី១ ១ដូស១០០,០០០ IU<br>ជីវជាតិអាថ្ងៃទី២ ១ដូស១០០,០០០ IU<br>ជីវជាតិអាថ្ងៃទី១៤ ១ដូស១០០,០០០ IU |
| | ១-១២ ឆ្នាំ | ជីវជាតិអាថ្ងៃទី១ ១ដូស២០០,០០០ IU<br>ជីវជាតិអាថ្ងៃទី២ ១ដូស២០០,០០០ IU<br>ជីវជាតិអាថ្ងៃទី១៤ ១ដូស២០០,០០០ IU |
| ភាពស្លេកស្លាំង បាតដៃមានភាព ស្លេកស្លាំងខ្លាំង | គ្រប់អាយុ ទាំងអស់ | មិនត្រូវផ្តល់ជាតិដែកទេ ត្រូវបញ្ជូនទៅកាន់មន្ទីរពេទ្យ |
| បាតដៃមាន ភាពស្លេកស្លាំង តិចតួច | ៤-១២ខែ (៦-<១០គក្រ) | ជាតិដែក/អាស៊ីដហ្វូលីក ១/៤ នៃដូស រយៈពេល១៤ថ្ងៃ។ ធ្វើការវាយតម្លៃ ឡើងវិញ បន្ទាប់ពីការព្យាបាល (១គ្រាប់មានជាតិដែក ៦០មក្រ និង អាស៊ីដហ្វូលីក ៤០០ មក្រក្រ) |
| | ១-៥ ឆ្នាំ (១០-១៩គក្រ) | ជាតិដែក/អាស៊ីដហ្វូលីក ១/២ នៃដូស រយៈពេល១៤ថ្ងៃ។ធ្វើការវាយតម្លៃ ឡើងវិញ បន្ទាប់ពីការព្យាបាល |

# ០៤

# ធ្វើការវាយតម្លៃនិងផ្តល់ប្រឹក្សាអំពីការបំបៅកូនដោយទឹកដោះម្តាយ ពិនិត្យមើលការដាក់មាត់ផ្ទឹបទៅនឹងដោះបានល្អសំរាប់កុមារអាយុតិចជាង៦ខែ



## សញ្ញានៃការរៀបចំស្ថានភាពបីបំបៅ និងការដាក់មាត់ផ្ទឹបទៅនឹងដោះបានល្អ



ការផ្ទឹបមាត់ទៅនឹងដោះបានល្អ

- ម្តាយមានសភាពសម្រាក និងផាសុកភាព
- រាងកាយរបស់ទារកនៅកៀកជាប់នឹងខ្លួនម្តាយដោយបែរទៅរកដោះ
- ក្បាល និងដងខ្លួនរបស់ទារកសណ្តូកត្រង់
- ចង្ការរបស់ទារកប៉ះទៅនឹងដោះ
- គូថរបស់ទារកត្រូវបានទ្រ
- មាត់របស់ទារក បើកធំ
- បបូរមាត់ខាងក្រោមរបស់ទារករលារចេញក្រៅ
- អណ្តាតរបស់ទារកក្តោបជុំវិញដោះ
- ថ្ពាល់របស់ទារកឡើងប៉ោង
- រង្វង់ខ្មៅជុំវិញដោះនៅក្នុងមាត់របស់ទារកច្រើន
- ទារកជញ្ជក់មួយៗ ខ្លាំងៗនិងសម្រាកម្តងៗ
- អាចមើលឃើញ ឬឮសូរសម្លេងលេបទឹកដោះ
- ទារកលែងឬខ្ទាក់ដោះចេញដោយឯងៗ
- ទារកមានសភាពសម្រាក និងងងុយគេង

## សាកសួរ ម្តាយអំពីការលំបាកក្នុងការបំបៅកូនដោយទឹកដោះម្តាយ ហើយធ្វើការផ្តល់ប្រឹក្សាទៅតាមបញ្ហាដែលមាន

| ការលំបាកដែលម្តាយជួបប្រទះ | សារសំរាប់ផ្តល់ប្រឹក្សា |
|---|---|
| ទឹកដោះមានមិនគ្រប់គ្រាន់ | បំបៅដោះកូនរាល់២-៣ម៉ោងម្តង។ ត្រូវហូបទឹកយ៉ាងហោចណាស់ឱ្យបាន ២ លីត្រ ក្នុងមួយថ្ងៃ។ ត្រូវបរិភោគអាហារបន្ថែមមួយពេលទៀតក្នុង ១ថ្ងៃ និងអាហារក្រៅពេលដែលសំបូរសារជាតិបំប៉នបន្ថែមទៀត ដូចជាផ្លែឈើជាដើម |
| លាសដោះ | ត្រូវយកក្រណាត់ស្អាតក្តៅឧណ្ហៗដាក់ស្អំពីលើដោះរយៈពេល ៥នាទីនៅមុនពេលបំបៅដោះកូនម្តងៗ។ បើទារកមានការពិបាកក្នុងការដាក់មាត់ផ្ទឹបទៅនឹងដោះ ច្របាច់ដោះថ្នមៗឱ្យទឹកដោះចេញខ្លះមុនដាក់ឱ្យកូនបៅ។ បំបៅកូនរៀងរាល់ ២-៣ម៉ោងម្តង ច្របាច់ទឹកដោះដែលនៅសល់ចេញ នៅក្រោយពេលបំបៅដោះរួចម្តងៗ។ |

| ការលំបាកដែលម្តាយជួបប្រទះ | សារសំរាប់ផ្តល់ប្រឹក្សា |
|---|---|
| **ក្បាលដោះមានស្នាមប្រេះ និងមានការឈឺចាប់** | រក្សាដោះឱ្យស្ងួត និងស្អាតជានិច្ចបន្ទាប់ពីបំបៅម្តងៗ។ ចាប់ផ្តើមបំបៅកូននៅខាងដែលមិនសូវឈឺមុន។ នៅពេលបញ្ចប់នៃការបំបៅ ផ្តាច់មាត់កូនពីដោះដោយថ្នមៗ។ |
| **ក្បាលដោះលឹបចូលក្នុង** (ដោះខ្វាក់) | យកតួសេរាំងបឺតទាញក្បាលដោះចេញក្រៅមុនពេលបំបៅដោះកូន។ |

**ផ្តល់ប្រឹក្សា ស្តីពីការបន្តការបំបៅកូនដោយទឹកដោះម្តាយ**

- បំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់ រយៈពេល៦ខែដំបូង។
- ចាប់ផ្តើមផ្តល់អាហារបន្ថែមចាប់ពីកុមារអាយុបាន ៦ខែ។
- បន្តធ្វើការបំបៅកូនដោយទឹកដោះម្តាយរហូតទាល់តែកុមារអាយុបានយ៉ាងតិច ២ឆ្នាំ ឬលើសពីនេះ។




**មើលទំព័រស្តីពីការផ្តល់អាហារបន្ថែម ដែលនៅទំព័រខាងក្រោយនៃសម្ភារៈជំនួយការងារនេះ**

## ០៥ ពិនិត្យមើលស្ថានភាពទទួលថ្នាំបង្ការរបស់កុមារ

**ផ្តល់ថ្នាំបង្ការដល់កុមារបើសិនជាចាំបាច់ ចូរប្រើតារាងខាងក្រោមនេះ**

| ក្រុមចំណុច | កំរិតដូស | កំណត់សម្គាល់ |
|---|---|---|
| ទារកទើបសម្រាល | **BCG** : តែ ១ ដូសគត់<br>**HBO** : តែ ១ ដូសគត់ | **BCG** អាចផ្តល់បានរហូតដល់កុមារអាយុ១ឆ្នាំក្រោយសម្រាល។ មិនត្រូវផ្តល់ទេ បើមានរោគសញ្ញាអេចអាយវី<br>**HBO** ត្រូវផ្តល់ក្នុងរយៈពេល២៤ម៉ោងក្រោយសម្រាល ប៉ុន្តែគេអាចផ្តល់បាននៅក្រោម៧ថ្ងៃ។ |

| ក្រុមចំណុច | កំរិតដូស | កំណត់សម្គាល់ |
|---|---|---|
| កុមារអាយុ ក្រោយ ៦សប្តាហ៍ ដល់១ឆ្នាំ | **OPV, DPT ឬ DPT-HB** ដូសទី១: ៦សប្តាហ៍ ក្រោយសម្រាល ដូសទី២:យ៉ាងហោច ណាស់៤សប្តាហ៍ ក្រោយពីដូសទី១ ដូសទី៣:យ៉ាងហោច ណាស់ ៤សប្តាហ៍ ក្រោយពីដូសទី២ **ជំងឺកញ្ជ្រិល** តែ ១ដូសគត់ យ៉ាងហោច ណាស់ អាយុ៩ខែ បន្ទាប់ពីសម្រាល | មិនត្រូវខកខានកាលបរិច្ឆេទក្នុងការ ផ្តល់ថ្នាំបង្ការណាមួយឡើយ។ថ្នាំបង្ការ នឹងមិនមានប្រសិទ្ធភាពឡើយប្រសិន បើមានការខកខានណាមួយនោះ។ ចំពោះ **DPT-HB** មិនត្រូវផ្តល់ឱ្យឡើយ នៅពេលណាកុមារមានជំងឺធ្ងន់ធ្ងរ ដោយមានកំដៅឡើងខ្ពស់លើសពី ៣៨,៥ អង្សាសេ។ មិនត្រូវផ្តល់ **DPT/DPT-HB** បើដឹង ថា កុមារធ្លាប់មានប្រតិកម្មជាមួយ នឹងថ្នាំបង្ការទាំងនេះ។ ត្រូវកត់ត្រា ការផ្តល់ថ្នាំបង្ការនេះទៅក្នុងប័ណ្ណ សុខភាពកុមារនិងក្នុងសៀវភៅ កត់ត្រារបស់មណ្ឌលសុខភាព។ |

## ០៦

## ផ្តល់ថ្នាំមេបង់ដាសុលបើកុមារមាន អាយុ ១២ខែ ឬលើសពីនេះ ហើយ មិនទាន់បានទទួលថ្នាំទម្លាក់ព្រូន នៅក្នុងរយៈពេល៦ខែមុន



| ក្រុមអាយុ | មេបង់ដាសុល |
|---|---|
| ១២-២៣ ខែ | ១/២ គ្រាប់ (=២៥០មក្រ)  |
| ២៤ ខែ និង លើសពីនេះ | ១ គ្រាប់ (=៥០០មក្រ)  |

## ០៧

## បំពេញប័ណ្ណសុខភាពកុមារ បំពេញបញ្ជីកត់ត្រារបស់មណ្ឌលសុខភាព

## ០៨

## ធ្វើការចរចា អំពីការត្រលប់មកពិនិត្យលើកក្រោយ

- មកមណ្ឌលសុខភាពដើម្បីពិនិត្យតាមដានសុខភាព (សូមរំលឹកប្រាប់អ្នកថែទាំកុមារ អំពីកាលបរិច្ឆេទសំរាប់ការពិនិត្យលើកក្រោយ)
- មកមណ្ឌលសុខភាព នៅពេលណាអ្នក ឬកូនរបស់អ្នកឈឺ



- រំលឹកប្រាប់ម្ដាយឱ្យយកប័ណ្ណសុខភាពកុមារមកជាមួយ នៅរាល់ពេលយកទទួលសេវាពិនិត្យថែទាំសុខភាព

**រំលឹកអំពីសារៈសំខាន់នៃការផ្ដល់បន្ថែមគ្រាប់ថ្នាំជីវជាតិអា ចំនួន២ដងក្នុង១ឆ្នាំ (នៅជុំវិញ ខែឧសភា និង ខែវិច្ឆិកា) នៅពេលកុមារមានអាយុ ចាប់ពី៦ខែ ដល់ ៥៩ខែ នៅសេវាតាមភូមិ ឬនៅមណ្ឌលសុខភាព។**

**"ជីវជាតិអា ជួយសង្គ្រោះជីវិតកុមារ"។**



## ការផ្ដល់អាហារដល់កុមារឈឺ

នៅពេលដែលកុមារឈឺគេតែងតែមិនឃ្លានចំណីអាហារ។ នេះជាការលំបាកណាស់ ពីព្រោះពួកគេត្រូវការសារជាតិចិញ្ចឹមនៅក្នុងចំណីអាហារ ដើម្បីជួយពួកគេឱ្យជាសះស្បើយពីជំងឺ។

### ០-៦ខែ

- ផ្ដល់ដំបូន្មានដល់ម្ដាយថា ទារកឈឺ ដែលមានអាយុតិចជាង៦ខែ គួរត្រូវបៅដោះម្ដាយឱ្យបានញឹកញាប់ថែមទៀត នៅក្នុងពេលដែលគេមានជំងឺ ហើយនិងរយៈពេល ២សប្ដាហ៍ក្នុងអំឡុងពេលជើបពីឈឺ
- ប្រសិនបើទារកមានរាក ហើយមានសញ្ញាបាត់បង់ជាតិទឹក (ភ្នែករូងបបូរមាត់ និងអណ្ដាតស្ងួត អត់មាននោម) ត្រូវបញ្ជូនទារកនោះជាបន្ទាន់ទៅកាន់មណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែកដែលនៅជិតជាងគេ ដើម្បីធ្វើការព្យាបាល។ ម្ដាយ និងអ្នកស្ម័គ្រចិត្តភូមិ គួរទទួលបានការអប់រំអំពីការសម្គាល់នៅសញ្ញាបាត់បង់ជាតិទឹក។



### កុមារអាយុពី ៦-៥៩ខែ

- កុមារឈឺដែលមានអាយុ ពី៦-៥៩ខែ គួរបង្កើនការបរិភោគជាតិទឹករួមទាំងការបៅដោះម្ដាយឱ្យបានញឹកញាប់ជាងសព្វដង នៅក្នុងពេលមានជំងឺ ហើយនិងរយៈពេល ២សប្ដាហ៍ក្នុងអំឡុងពេលជើបពីឈឺ។
- អ្នកថែទាំគួរលើកទឹកចិត្តកុមារឈឺឱ្យបរិភោគអាហារទន់ៗ ផ្សេងៗគ្នា អាហារដែលគេចូលចិត្ត។ ផ្ដល់បរិមាណអាហារតិចៗ តែឱ្យញឹកញាប់ ៥-៦ពេល។ កុមារគួរបរិភោគអាហារប្រភេទផ្សេងៗ។ ផ្លែឈើ បន្លែ និងផលិតផលសត្វ នឹងជួយកុមារឱ្យមានភាពធូរស្រាលបានយ៉ាងលឿន។
- បន្ទាប់ពីឈឺ កុមារត្រូវបរិភោគអាហារពេល បន្ថែមមួយពេលក្នុងមួយថ្ងៃ រយៈពេល២សប្ដាហ៍ (រយៈពេលជើបពីឈឺ)
- ម្ដាយ និងអ្នកស្ម័គ្រចិត្តនៅក្នុងសហគមន៍ គួរត្រូវបានអប់រំពីរបៀបលាយ និងផ្ដល់អូរ៉ាលីត្រដល់កុមារដែលមានរាក។
- ប្រសិនបើកុមារមានរាកធ្ងន់ធ្ងរ មានសញ្ញាបាត់បង់ជាតិទឹក (ភ្នែករូងបបូរមាត់ និងអណ្ដាតស្ងួត អត់មាននោម) ត្រូវបញ្ជូនកុមារនោះជាបន្ទាន់ទៅកាន់មណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែកដែលនៅជិតជាងគេ ដើម្បីធ្វើការព្យាបាល។

គោលការណ៍ណែនាំ ការផ្តល់អាហារបន្ថែម



# ជុំចែកចាយ
# គ្រាប់ថ្នាំជីវជាតិអា



## ជីវជាតិអាជួយ
## សង្គ្រោះជីវិតកុមារ



ជុំចែកចាយ
គ្រាប់ថ្នាំជីវជាតិអា

រាក់ទាក់
ញញឹម
ស្តាប់

## ០១ សាកសួររកប័ណ្ណសុខភាពកុមារ ពិនិត្យមើលព័ត៌មាននៅលើប័ណ្ណសុខភាពកុមារ

## ០២ ផ្ដល់ដល់កុមារអាយុ ៦ខែ – ៥៩ ខែនូវគ្រាប់ថ្នាំជីវជាតិអា និង មេបង់ដាសុល ដោយយោងទៅតាមតារាងដូចខាងក្រោមនេះ

| ក្រុមចំណុច | កំរិតដូសជីវជាតិអា | មេបង់ដាសុល |
|---|---|---|
| កុមារអាយុ<br>៦-១១ ខែ | ១០០.០០០ IU  | *មិនផ្ដល់មេបង់ដាសុលទេ* |
| កុមារអាយុ<br>១២ -៥៩ ខែ | ២០០.០០០ IU  | ១២- ២៣ ខែ<br>១/២ គ្រាប់<br>(= ២៥០ មក្រ)<br>នៃគ្រាប់ថ្នាំមេបង់ដាសុល  |
| | | ២៤ -៥៩ ខែ<br>១គ្រាប់<br>(=៥០០ មក្រ)<br>នៃគ្រាប់ថ្នាំមេបង់ដាសុល  |

*នៅពេលដែលអ្នកផ្ដល់គ្រាប់ថ្នាំជីវជាតិអា ដល់កុមារណាម្នាក់ សូមប្រាប់ដល់អ្នកថែទាំកុមារនោះថា អ្នកផ្ដល់គ្រាប់ថ្នាំជីវជាតិអាឱ្យកុមារនោះ និងពន្យល់ទៀតថា ជីវជាតិអាជួយសង្គ្រោះជីវិតកុមារ*

## ០៣ ផ្ដល់ដល់ស្ត្រីក្រោយសម្រាលនូវគ្រាប់ថ្នាំជីវជាតិអា មេបង់ដាសុល និងជាតិដែក/អាស៊ីដហ្វូលីកនៅចន្លោះពេល ៦សប្តាហ៍ដំបូងបន្ទាប់ពីសម្រាល

| ជីវជាតិអា  | មេបង់ដាសុល  | ជាតិដែក/<br>អាស៊ីដហ្វូលីក  |
|---|---|---|
| ១គ្រាប់(២០០,០០០ IU) ដល់ស្ត្រីក្រោយសម្រាល នៅចន្លោះពេល៦សប្ដាហ៍ដំបូងបន្ទាប់ពីសម្រាល។<br>ទៅមណ្ឌលសុខភាព បើសិនជាមានសញ្ញាកង្វះជីវជាតិអា | មេបង់ដាសុល ១ដូស (៥០០មក្រ) | ៤២គ្រាប់ប្រសិនបើមិនទាន់បានទទួលនៅពេលសម្រាល<br>១គ្រាប់ក្នុង១ថ្ងៃ<br>ពន្យល់អំពីផលរំខាននៃថ្នាំ លាមកខ្មៅ មានអារម្មណ៍មិនស្រួលខ្លួន ចង្អោរ រាក ឬទល់លាមក |

| | | |
|---|---|---|
| | | ពន្យល់ថា ផលរំខាននៃថ្នាំនេះ ពុំបណ្ដាលឱ្យមានគ្រោះថ្នាក់អ្វីទេ។ ធ្វើការណែនាំឱ្យគាត់លេបថ្នាំនេះ នៅពេលបាយ ឬពេលចូលគេង<br>ណែនាំអំពីអាហារសំបូរជាតិដែក។<br>ណែនាំអោយបរិភោគអាហារសំបូរវីតាមីន ដូចជា ផ្លែឈើ និងបន្លែ (១គ្រាប់មាន ជាតិដែក ៦០មក្រ និងអាស៊ីដហ្វូលីក ៤០០មក្រក្រ) |

*កត់ត្រាលើសៀវភៅសុខភាពមាតា សន្លឹកកត់ត្រា និងបញ្ជីកត់ត្រារបស់មណ្ឌលសុខភាពនៅពេលស្ត្រីក្រោយសម្រាល ទទួលគ្រាប់ថ្នាំជីវជាតិអា មេបង់ដាសុល និងជាតិដែក/អាស៊ីដហ្វូលីក*

## ០៤ ផ្ដល់ប្រឹក្សាអំពីអាហារសំបូរជីវជាតិអា



### ផ្ដល់ដំបូន្មានដល់ម្ដាយ:

- គ្រប់គ្រួសារទាំងអស់គួរបរិភោគអាហារសំបូរដោយជីវជាតិអា
- **ជីវជាតិអាជួយសង្គ្រោះជីវិតកុមារ ពីព្រោះវាការពារកុមារពីជំងឺកុមារភាពដែលជួបញឹកញាប់**
- ជីវជាតិអា កាត់បន្ថយភាពធ្ងន់ធ្ងរនៃជំងឺបង្ករោគ ជាពិសេស ជំងឺកញ្ជ្រិល និងជំងឺរាករ៉ាំរ៉ៃ ដោយកាត់បន្ថយនូវអត្រាចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យ និងការមកពិនិត្យជំងឺក្រៅ

### អាហារសំបូរដោយជីវជាតិអា

- ស៊ុត ត្រី សាច់ និងថ្លើម
- បន្លែ និងផ្លែឈើពណ៌លឿងទុំ: ឧទាហរណ៍ ល្ពៅ ការ៉ុត ដំឡូងជ្វា សាច់ពណ៌លឿង ល្ហុង និងស្វាយទុំ
- បន្លែស្លឹកពណ៌បៃតងចាស់: ឧទាហរណ៍ ស្ពៃ ស្លឹកដំឡូងមី ស្លឹកសណ្ដែក និង ស្លឹកល្ពៅ
- ប្រេងដូងក្រហម



## សារគន្លឹះ: "ជីវជាតិអាជួយសង្គ្រោះជីវិតកុមារ"

| ស្ត្រី | ទារក ០-៦ ខែ | ទារក ៦-៥៩ ខែ |
|---|---|---|
| បរិភោគអាហារសំបូរជីវជាតិអា និងបង្កើនផលិតផល សួនដំណាំគ្រួសារ ផ្តល់គ្រាប់ថ្នាំជីវជាតិអា១គ្រាប់ (២០០,០០០ IU) ដល់ស្ត្រីនៅក្នុងចន្លោះពេល ៦ សប្តាហ៍ដំបូងក្រោយសម្រាល ទៅមណ្ឌលសុខភាព បើសិនជាមានចេញសញ្ញាកង្វះជីវជាតិអា | ចាប់ផ្តើមធ្វើការបំបៅកូនដោយទឹកដោះម្តាយភ្លាមក្នុងម៉ោងដំបូងបន្ទាប់ពីសម្រាល បំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់រហូតដល់អាយុ ៦ខែ ទៅមណ្ឌលសុខភាព ឬសេវាមូលដ្ឋាន ដើម្បីទទួលថ្នាំបង្ការ និងការថែទាំសុខភាព | បន្តបំបៅកូនដោយទឹកដោះម្តាយយ៉ាងហោចណាស់រហូតកុមារអាយុបាន ២ឆ្នាំ ផ្តល់អាហារបន្ថែមសមស្របចាប់ពីកុមារអាយុ ៦ខែ ផ្តល់គ្រាប់ថ្នាំជីវជាតិអា និងមេបង់ដាសុល នៅរៀងរាល់ ៦ខែម្តង ទៅមណ្ឌលសុខភាពបើសិនជាមានចេញសញ្ញាកង្វះជីវជាតិអា ឬឈឺ |

## ០៥

### ផ្តល់ប្រឹក្សាអំពីការបំបៅកូនដោយទឹកដោះម្តាយ និងការផ្តល់អាហារបន្ថែម



ចាប់ផ្តើមផ្តល់អាហារបន្ថែមចាប់ពីកុមារអាយុបាន ៦ខែ។ បន្តធ្វើការបំបៅកូនដោយទឹកដោះម្តាយ រហូតទាល់តែកុមារអាយុបានយ៉ាងតិច ២ឆ្នាំ ឬលើសពីនេះ។




អនុវត្តទៅតាមអនុសាសន៍ នៃការផ្តល់អាហារបន្ថែម ដែលមានបង្ហាញជូននៅទំព័របន្ទាប់នៃសម្ភារៈជំនួយការងារ។ សូមឱ្យប្រាកដថា គ្រប់អាហារនៅក្នុងក្រុមអាហារទាំងអស់ត្រូវបានបញ្ចូលនៅក្នុងរបបអាហារ។

## ០៦



បំពេញប័ណ្ណសុខភាពកុមារ–សូមរំលឹកប្រាប់អ្នកថែទាំកុមារអំពីជុំបន្ទាប់នៃការផ្តល់បន្ថែមគ្រាប់ថ្នាំជីវជាតិអា (នៅជុំវិញខែឧសភានិងខែវិច្ឆិកាជារៀងរាល់ឆ្នាំ)។
រំលឹកប្រាប់ម្តាយអោយយកប័ណ្ណសុខភាពកុមារមកជាមួយរាល់ពេលយកកូនមកទទួលសេវាពិនិត្យថែទាំសុខភាព។
បំពេញបញ្ជីកត់ត្រារបស់មណ្ឌលសុខភាពដោយចំលងចេញពីសន្លឹកកត់ត្រា បើសិនជាធ្វើការនៅតាមភូមិ។

## គោលការណ៍ណែនាំ ការផ្តល់អាហារបន្ថែម



សម្ភារៈជំនួយការងារនេះត្រូវបានរចនា និងបោះពុម្ពដោយមានការឧបត្ថម្ភថវិកា
ពីទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID)
តាមរយៈគំរោងមីក្រូសារជាតិ A2Z

Design by **nova**: info@novacambodia.com